# ការអប់រំទូទៅ (ភាគ១)




**រៀបរៀងដោយ៖** គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ៖

**“មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍”**

**២០២២**

**គណៈកម្មការនិពន្ធ៖**

១. លោកបណ្ឌិត សាំង មាសសួន

២. លោកស្រី អ៊ូ ស៊ីថា

៣. លោកស្រី ធុំ គន្ធី

៤. លោកស្រី ជិន ភីនី

៥. លោកស្រី អ៊ុយ វណ្ណៈ

៦. លោកស្រី គង់ ស្រីលីន

**គណៈកម្មការរចនាទំព័រ៖** លោកស្រី សំបាត់ អ៊ាត លោកស្រី ឈុំ ពៅ

**គណៈកម្មការត្រួតពិនិត្យ៖**

១. លោកបណ្ឌិត សំ ច័ន្ទកិរុណា

# មុខកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀតអត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ក៏កំពុងលេចរូបរាងឡើងដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេស មានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោក និងតំបន់រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជាដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានកំពុងបន្តពង្រឹង និងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវ និងនវានុវត្តន៍ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជាឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាង ហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវ និងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូវ និងអាហ្វ្រិកមានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោកក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ប្រទេសចំនួន ៦ ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍរួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះចាំបាច់

តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ចពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិតជ្រើសរើសបន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះអាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទា ក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជា មូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យា និងតំណភ្ជាប់បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះការអប់រំនឹងបន្តវិវត្តទៅមុខ និងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយ ពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតបចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជា ស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិក និងសារ-គមនាគមន៍ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ទនគីមី

សាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក លក្ខណៈសម្បត្តិនៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើ គ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយ គុណាធិបតេយ្យ និងជាពិសេស គឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថាន សិក្សាដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណា ទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរ និងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន ៣០៥ពាន់ និងប្រទេស រុស្ស៊ីមាន ១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស និស្សិត និងសាធារណៈជនរួមមានការអានសៀវភៅ ការអានលើឧបករណ៍ អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណាន ដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយ កម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណាន កំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជា បច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំ ឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេស ការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយដើម្បីលើកកម្ពស់អំណានតាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សាឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

1. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀតដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

2. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

3. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀន បង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវ បណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន

4. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថល ជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សា អាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណាន កាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន

5. និស្សិតគ្រប់កម្រិតសិក្សា ត្រូវខិតខំនិងចំណាយពេលអាន និងចាត់ទុកវប្បធម៌ និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ

6. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា"មូលនិធិ ស.គ.ន" និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមាន ឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.០(Digitalization for IR.4.0)ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សរ៍ទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពរូបនីយកម្មទៅលើទិសដៅនៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការ**រៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា(Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា**។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា

ជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀតការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

- ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សាដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា
- លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
- បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈ និងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
- រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់ នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធ អេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិរួចសូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋនិងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំសូមចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូច និងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# សេចក្ដីបញ្ជាក់

## នៃមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោង រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សានេះត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្ដល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ និងរូបភាព គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំខ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិការស្រាវជ្រាវ គណិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# មាតិកា

ទំព័រ


សេចក្ដីបញ្ជាក់ ........ Error! Bookmark not defined.

អារម្ភកថា ........ 16

សេចក្ដីថ្លែងអំណរគុណ ........ 17

ការបរិយាយលើមុខវិជ្ជា ........ 18

មូលន័យសង្ខប ........ 19

មេរៀនទី១ ........ 20

១.១ វត្ថុបំណង៖ ........ 20

១.២ សេចក្ដីផ្ដើម៖ ........ 20

១.៣.១ តម្រូវការ និងសិទ្ធិ ........ 20

១.៣.២ តើអ្វីជាអនុសញ្ញាស្តីពីសិទ្ធិរបស់កុមារ ? ....20
១.៣.៣ មូលហេតុនៃការបង្កើតអនុសញ្ញាស្តីពីសិទ្ធិកុមារ....21
១.៣.៤ ដំណើរការបង្កើតអនុសញ្ញាស្តីពីសិទ្ធិកុមារ ....22
១.៣.៥ អ្វីជាការផ្តល់សច្ចាប័ន ?....23
១.៣.៦ លក្ខណៈពិសេសនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ....23
១.៣.៧ មាត្រាស្តីពីទណ្ឌកម្មកុមារ និងការជួញដូរកុមារ....24
១.៤ សន្និដ្ឋាន ....25
២.១ វត្ថុបំណង....27
២.២ សេចក្តីផ្តើម ....27
២.៣ ខ្លឹមសារ....27
២.៣.១ ពេស្យាចារលើកុមារ....27
២.៣.២.ការជួញដូរកុមារ....28
២.៣.៣ ការកេងប្រវ័ញ្ច ....28
២.៣.៤ ការរំលោភបំពានផ្លូវភេទ ....28
២.៣.៥ រូបភាពអាសអាភាស ផ្លូវភេទប្រើប្រាស់ទៅលើកុមារ ....29
២.៤ សន្និដ្ឋាន....29
មេរៀនទី៣៖ ....31
វិធីដែលកុមារអាចប្រើដើម្បីការពារខ្លួន និងមិត្តភក្តិ....31
ពីការរំលោភផ្លូវភេទ ....31
៣.១ វត្ថុបំណង ....31
៣.២ សេចក្តីផ្តើម....31

៣.៣ ខ្លឹមសារ ........................................................................................ 31

៣.៣.១ វិធីដែលកុមារអាចប្រើ ........................................................................ 31

៣.៣.២ លេខទូរស័ព្ទសង្គ្រោះបន្ទាន់ថ្នាក់ជាតិ និងខេត្ត-ក្រុងមួយចំនួន ........................................ 33

៣.៤ សន្និដ្ឋាន ........................................................................................ 33

មេរៀនទី៤ ........................................................................................ 35

ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ........................................................ 35

( Education for Sustainable Development ) ........................................................ 35

" បញ្ហាសង្គម សេដ្ឋកិច្ច និងបរិស្ថាន " ........................................................ 35

៤.១ វត្ថុបំណង ........................................................................................ 35

៤.២ សេចក្តីផ្តើម ........................................................................................ 35

៤.៣ ខ្លឹមសារ ........................................................................................ 35

៤.៣.១ បញ្ហាសង្គម សេដ្ឋកិច្ច និងបរិស្ថាន ........................................................ 35

៤.៣.២ គោលដៅនិងវត្ថុបំណងនៃការអប់រំបរិស្ថាន ................................................ 37

៤.៣.៣ ការអប់រំបរិស្ថាន ........................................................................ 37

៤.៣.៤ ការបំលែងការអប់រំបរិស្ថានទៅជាការអប់រំសម្រាប់ការអភិវឌ្ឍប្រកប ដោយចីរភាព ......... 38

៤.៣.៥ ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព( អន្តរទំនាក់ទំនងរវាង សង្គម សេដ្ឋកិច្ច និងបរិស្ថាន ) ........................................................................ 38

៤.៤ សន្និដ្ឋាន ........................................................................................ 39

មេរៀនទី៥ ........................................................................................ 41

៥.១ វត្ថុបំណង ........................................................................................ 41

៥.២ សេចក្តីផ្តើម ........................................................................................ 41

៥.៣ ខ្លឹមសារ ..................................................................................................................... 41
៥.៣.១ បញ្ហានៃការអប់រំបច្ចុប្បន្ននៅកម្ពុជា ....................................................................... 41
៥.៣.២ ការអប់រំសម្រាប់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពនៅឆ្នាំ២០៣០ ........................42
៥.៣.៣ កម្មវិធីសកម្មភាពជាសាកលស្តីពីការអប់រំសម្រាប់គោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាព ..........................................................................................................................45
៥.៤ សន្និដ្ឋាន ...................................................................................................................46
មេរៀនទី៦ .......................................................................................................................48
៦.១ វត្ថុបំណង.....................................................................................................................48
៦.២ សេចក្តីផ្តើម ..................................................................................................................48
៦.៣ ខ្លឹមសារ .......................................................................................................................48
៦.៣.១ សេចក្តីផ្តើមនៃការអប់រំបរិស្ថាន ..............................................................................48
៦.៣.២ គោលដៅនិងវត្ថុបំណងនៃការអប់រំបរិស្ថាន.................................................................49
៦.៣.៣ ការបំលែងការអប់រំបរិស្ថានទៅជាការអប់រំសម្រាប់ការអភិវឌ្ឍ ប្រកបដោយចីរភាព ........50
៦.៤ សន្និដ្ឋាន ...................................................................................................................51
មេរៀនទី៧.......................................................................................................................53
៧.១ វត្ថុបំណង ...................................................................................................................53
៧.២ សេចក្តីផ្តើម..................................................................................................................53
៧.៣ ខ្លឹមសារ.......................................................................................................................53
៧.៣.១ បញ្ញត្តិនៃការអភិវឌ្ឍប្រកបដោយចីរភាព.......................................................................53
៧.៣.២ គោលបំណងនៃការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព.....................................53
៧.៣.៣ ចក្ខុវិស័យថ្មីសម្រាប់វិស័យអប់រំឆ្ពោះទៅកាន់ឆ្នាំ ២០៣០ ...........................................54

៧.៣.៤ ធាតុសំខាន់ៗនៃការអប់រំដើម្បីសម្រេចចក្ខុវិស័យថ្មីឆ្ពោះទៅរកគោលដៅ អប់រំឆ្នាំ២០៣០ 55
៧.៤ សន្និដ្ឋាន ........ 55
មេរៀនទី ៨ ........ 57
៨.១ វត្ថុបំណង ........ 57
៨.២ សេចក្តីផ្តើម ........ 57
៨.៣ ខ្លឹមសារ ........ 57
៨.៣.១ របាយការណ៍សុភមង្គលពិភពលោក ........ 57
៨.៣.២ ប្រទេសទាំង១០ដែលមានសុភមង្គលល្អបំផុតក្នុងឆ្នាំ ២០១៨ និង ២០១៩ ........ 58
៨.៣.៣ ប្រទេសដែលមានសុភមង្គលជាងគេបំផុតលើពិភពលោក ........ 58
៨.៣.៤ របាយការណ៍សុភមង្គលពិភពលោកចំណាត់ថ្នាក់ប្រទេសអាស៊ីអាគ្នេយ៍ ក្នុងឆ្នាំ ២០១៩ .60
៨.៤ សន្និដ្ឋាន ........ 61
៩.១ វត្ថុបំណង ........ 63
៩.២ សេចក្តីផ្តើម ........ 63
៩.៣ ខ្លឹមសារ ........ 63
៩.៣.១ ជំនាញសតវត្សរ៍ទី២១ ........ 63
៩.៣.២ ជំនាញសំខាន់ៗនៃសតវត្សរ៍ទី ២១ សម្រាប់សិស្សានុសិស្ស ........ 64
៩.៤ សន្និដ្ឋាន ........ 76
១០.១ វត្ថុបំណង ........ 77
១០.២ សេចក្តីផ្តើម ........ 77
១០.៣ ខ្លឹមសារ ........ 77
១០.៣.១ និយមន័យសាលាកុមារមេត្រី ........ 77

១០.៣.២ សមាសភាគទាំង៦នៃសាលាកុមារមេត្រី ....................................................78
១០.៤ សន្និដ្ឋាន ..........................................................................................85
មេរៀនទី១១ .............................................................................................87
១១.១.វត្ថុបំណង ...........................................................................................87
១១.២ សេចក្ដីផ្ដើម.........................................................................................87
១១.៣ ខ្លឹមសារ ..............................................................................................87
១១.៣.១ គុណវុឌ្ឍិរបស់គ្រូបង្រៀនសាលាកុមារមេត្រី ...................................................87
១១.៣.២ ប្រភេទនៃល្បែងសិក្សា ..............................................................................89
១១.៤ សន្និដ្ឋាន ..............................................................................................91
មេរៀនទី១២ .............................................................................................93
១២.១ វត្ថុបំណង.............................................................................................93
១២.៣.១ ប្រព័ន្ធ និងរចនាសម្ព័ន្ធក្នុងស្រុក ជាតិ និងសកល...........................................93
១២.៣.២ បញ្ហាដែលជះឥទ្ធិពលដល់អន្តរកម្ម និងទំនាក់ទំនងនៃសហគមន៍ក្នុង ស្រុក ជាតិ និងសកល ...........................................................................................95
១២.៣.៣ ការសន្មតជាមូលដ្ឋាន និងសក្ដានុពល ......................................................96
មេរៀនទី១៣.............................................................................................100
១៣.៣.១ ភាពខុសគ្នានៃអត្តសញ្ញាណ.......................................................................100
១៣.៣.២ ភាពខុសគ្នានៃសហគមន៍ដែលប្រជាជនរស់នៅ និងរបៀបផ្សារភ្ជាប់ របស់ពួកគេ...... 101
១៣.៣.៣ ភាពខុសគ្នា និងការគោរពចំពោះការចម្រុះ.................................................103
១៣.៤ សន្និដ្ឋាន..............................................................................................105
សំណួរ......................................................................................................106

មេរៀនទី ១៤ ........ 107
ការអប់រំភាពជាពលរដ្ឋសកល ........ 107
(រួមបញ្ចូលប្រភេទទាំង៣ PINK ទៅក្នុងខ្លឹមសារមេរៀន ១ ម៉ោង) ........ 107
១៤.៣.១ សកម្មភាពដែលធ្វើឡើងដោយឯកជន និងរួមគ្នា ........ 107
១៤.៣.២ អាកប្បកិរិយាប្រកបដោយសីលធម៌ ........ 109
១៤.៣.៣ ការផ្សារភ្ជាប់ និងការធ្វើសកម្មភាព ........ 111
មេរៀនទី ១៤ ........ 115
១៤.១ វត្ថុបំណង ........ 115
១៤.២ សេចក្តីផ្តើម ........ 115
១៤.៣ ខ្លឹមសារ ........ 115
១៤.៣.១ សកម្មភាពដែលធ្វើឡើងដោយឯកជន និងរួមគ្នា ........ 115
១៤.៣.២ អាកប្បកិរិយាប្រកបដោយសីលធម៌ ........ 117
១៤.៣.៣ ការផ្សារភ្ជាប់ និងការធ្វើសកម្មភាព ........ 119
១៤.៤ សន្និដ្ឋាន ........ 121
មេរៀនទី ១៥ ........ 123
ការបង្រៀនពីវិធីសាស្ត្រ និងបច្ចេកទេសក្នុងការអប់រំជាពលរដ្ឋសកល ........ 123
១៥.១ វត្ថុបំណង ........ 123
១៥.២ សេចក្តីផ្តើម ........ 123
១៥.៣ ខ្លឹមសារ ........ 123
១៥.៣.១ វិធីសាស្ត្រក្នុងការអប់រំភាពជាពលរដ្ឋសកល ........ 123
១៥.៣.២ បច្ចេកទេសក្នុងការអប់រំភាពជាពលរដ្ឋសកល ........ 125

១៥.៣.៣ សារៈសំខាន់ក្នុងការអប់រំភាពជាពលរដ្ឋសកល ..... 125

១៥.៤ សន្និដ្ឋាន ..... 125

# អារម្ភកថា

សៀវភៅ "ការអប់រំទូទៅ (ភាគ១)" នេះបានបង្កើតឡើងក្នុងគោលបំណងជួយ សម្រួលដល់ការសិក្សាស្រាវជ្រាវ របស់គរុនិស្សិត ១២ + ៤ ដើម្បីងាយសិក្សាស្វែងយល់នូវខ្លឹមសារ ក្នុងនោះរួមមានមូលដ្ឋានចំណេះដឹងស្តីពីសិទ្ធិកុមារ ច្បាប់ និងសន្ធិសញ្ញាដែលទាក់ទងទៅ នឹងសិទ្ធិ កុមារ ការបង្រៀនទាក់ទងនឹងការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព (ESD) កម្មវិធីសាលាកុមារមេត្រី ជំនាញសតវត្សរ៍ទី២១ និងការអប់រំអំពីពលរដ្ឋសកល (GCE)។

ការអភិវឌ្ឍន៍ឯកសារនេះយើងខ្ញុំបានខិតខំស្វែងរកនូវប្រភពទិន្នន័យជាច្រើនដែលទាក់ទងនឹងខ្លឹមសារប្រធានបទខាងលើមករួមបញ្ចូលគ្នាដោយប្រភពឯកសារដែលពាក់ព័ន្ធនោះ រួមមានឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡា ឯកសារក្នុងបណ្ណាល័យវិទ្យាស្ថានគរុកោសល្យ និងទិន្នន័យ ខ្លះទៀតប្រមូលពីអ៊ីនធើណែតដែលជាប្រព័ន្ធផ្សព្វផ្សាយមួយមានភាពទូលំទូលាយសម្រាប់សតវត្សរ៍ទី២១នេះ ដើម្បីបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អ។

ទោះបីយ៉ាងណាក៏ដោយ យើងខ្ញុំទទួលស្គាល់ថាឯកសារនេះនៅមិនទាន់ល្អឥតខ្ចោះនោះទេ ប្រាកដជាមានចំណុចខ្វះខាតជាច្រើនទៀតនឹងត្រូវកែសម្រួលបន្ថែមទៅតាមពេលវេលានិងការរីកចម្រើនរបស់វិស័យអប់រំ។

យើងខ្ញុំរង់ចាំទទួលនូវយោបល់រិះគន់ក្នុងន័យស្ថាបនាពីមិត្តអ្នកអាននិងអ្នកប្រើប្រាស់ទាំងអស់ដោយក្តីរីករាយ ដើម្បីជាទុនសម្រាប់កែលម្អឯកសារនេះឱ្យកាន់តែប្រសើរឡើងថែមទៀត។

# សេចក្តីថ្លែងអំណរគុណ

ជាការពិតសៀវភៅ «**ការអប់រំ ( ភាគ១ )**» ដែលលេចចេញជារូបរាងនៅពេលនេះគឺបានកើតឡើងពីការខិតខំ និងយកចិត្តទុកដាក់ចូលរួមពីភាគី និងស្ថាប័នពាក់ព័ន្ធជាច្រើន។

យើងខ្ញុំ/ខ្ញុំបាទ/នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ភាគីនិងស្ថាប័នពាក់ព័ន្ធទាំងអស់ដូចជា៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបានគាំទ្រយ៉ាងពេញទំហឹងដល់ក្រសួងអប់រំ យុវជន និងកីឡា ឱ្យបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ហៅកាត់ថា «មូលនិធិ ស.គ.ន»។
- ក្រសួងអប់រំ យុវជន និងកីឡាដែលបានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ដែលហៅកាត់ថា «មូលនិធិ ស.គ.ន» ដើម្បីរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។
- លនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលបានគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសាជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។
- ឯកឧត្តមបណ្ឌិតនាយកវិទ្យាស្ថានគរុកោសល្យភ្នំពេញ ដែលបានចាត់តាំងជាគណៈកម្មការនិពន្ធចូលរួមការរៀបរៀង និពន្ធ និងកែលម្អសៀវភៅនៅកម្រិតឧត្តមសិក្សានេះ។
- នាយកដ្ឋានបណ្តុះបណ្តាលដែលបានចាត់តាំងជាគណៈកម្មការនិពន្ធនិងគណៈកម្មការត្រួតពិនិត្យលើស្នាដៃនៃការចូលរួមការរៀបរៀងនិពន្ធ និងកែលម្អសៀវភៅនៅកម្រិតឧត្តមសិក្សានេះ។
- លោកប្រធាននាយកដ្ឋានបណ្តុះបណ្តាលដែលព្រមព្រៀងទទួលសិទ្ធិជាតំណាងអ្នករៀបរៀងក្នុងការចាត់ចែង និងសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងកិច្ចដំណើការទូទាត់ថវិកាតាមរយៈការស្នើសុំ និងទទួលថវិកា បោះពុម្ព និងផ្សព្វផ្សាយបន្តនូវស្នាដៃរៀបរៀង និពន្ធ និងកែលម្អរបស់អ្នករៀបរៀងក្នុងការរៀន និងបង្រៀនក្នុងគ្រឹះស្ថានសិក្សា និងប្រគល់សិទ្ធិស្របតាមការកំណត់នៃកិច្ចព្រមព្រៀង ស្តីពីការរៀបរៀង និពន្ធ និងកែលម្អសៀវភៅនៅកម្រិតឧត្តមសិក្សា ក្រោមការគាំទ្រនៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។
- គ្រូឧទ្ទេសមុខវិជ្ជា......នៃវិទ្យាស្ថាន..... ដែលបានផ្តល់មតិកែលម្អលើខ្លឹមសារ នៃមេរៀននីមួយៗ ឱ្យកាន់តែមានភាពសុក្រឹត និងមានលក្ខណៈវិទ្យាសាស្ត្រ។

យើងខ្ញុំសង្ឃឹមថាសៀវភៅនេះនឹងឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សាដែលជា

តម្រូវការសិក្សារបស់សិស្ស និស្សិត នៅកម្រិតវិទ្យាល័យ និងឧត្តមសិក្សា។

## ការបរិយាយលើមុខវិជ្ជា

ការអប់រំទូទៅ (ភាគ១) ជាមុខវិជ្ជាផ្តោតលើខ្លឹមសារសំខាន់ៗដូចជា អនុសញ្ញាស្តីពីសិទ្ធិកុមារ និងច្បាប់ទាក់ទងនឹងការដាក់ទណ្ឌកម្ម ការជួញដូរ ការកេងប្រវ័ញ្ចផ្លូវភេទកុមារ ប្រវត្តិនៃការអប់រំ សម្រាប់ការអភិវឌ្ឍ ប្រកបដោយចីរភាព (ESD) " បញ្ហានៃការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព (ESD) ទាក់ទងនឹងចក្ខុវិស័យ និងការអប់រំក្នុងឆ្នាំ ២០៣០ ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព (ESD) សន្ទស្សន៍នៃសុភមង្គល ពិភពលោក ប្រទេស Finland ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព (ESD) " ជំនាញក្នុងសតវត្សរ៍ទី ២១ កម្មវិធីសាលាកុមារមេត្រី និង សមាសភាគទាំង ៦ នៃ សាលាកុមារមេត្រី គ្រូបង្រៀនកម្មវិធីសាលាកុមារមេត្រី និងការអភិវឌ្ឍន៍ល្បែងសិក្សា ការអប់រំពលរដ្ឋសកល (ការដាក់បញ្ចូលគោលគំនិត BLUE ទាំងបីក្នុងខ្លឹមសារមួយម៉ោង) ការអប់រំពលរដ្ឋសកល (ការការបញ្ចូលគោលគំនិត PINK ទាំងបីក្នុងខ្លឹមសារមួយម៉ោង) ការអប់រំពលរដ្ឋសកល (ការបញ្ចូលគោលគំនិត GREEN ទាំងបីក្នុងខ្លឹមសារមួយម៉ោង) ពីវិធីសាស្រ្ត និងបច្ចេកទេសបង្រៀនសម្រាប់ការអប់រំពលរដ្ឋសកល ដែលកំពុងតែមានសារៈសំខាន់នៅក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈជាគ្រូបង្រៀន ។

# មូលន័យសង្ខេប

មុខវិជ្ជាការអប់រំទូទៅ ជាផ្នែកមួយនៃការសិក្សាអប់រំ ដែលមានចំនួន២ផ្នែក។ ផ្នែកទី១ ទាក់ទងនឹងសិទ្ធិកុមារ ច្បាប់ និងសន្ធិសញ្ញាដែលទាក់ទងទៅនឹងសិទ្ធិកុមារ ការអប់រំសម្រាប់ការអភិវឌ្ឍប្រកប ដោយចីរភាព ( ESD ) កម្មវិធីសាលាកុមារមេត្រី ការអប់រំអំពីពលរដ្ឋសកល ( GCE )។

ផ្នែកទី២ នៃមុខវិជ្ជាទាក់ទងទៅនឹងប្រធានបទដូចជា : ការអប់រំ និងយេនឌ័រ , ការអប់រំបរិយាបន្ន ការបង្រៀនថ្នាក់គួប ការប្រើប្រាស់គ្រឿងញៀន បំណិនក្នុងការសិក្សា និងគំនិតមូលដ្ឋានអំពី មគ្គុទ្ទេសក៍អាជីព និងផ្តល់ការប្រឹក្សា ( CGC ) ។

មុខវិជ្ជាការអប់រំទូទៅជាមុខវិជ្ជារង១នៅក្នុងមុខវិជ្ជាការសិក្សាអប់រំដែលគរុនិស្សិតត្រូវសិក្សានៅឆ្នាំទី១ ឆមាសទី ១ មានចំនួន ១ ក្រេឌីត ស្មើនឹង ១៥ ម៉ោង ។

# មេរៀនទី១
# អនុសញ្ញាស្តីពីសិទ្ធិកុមារ និងច្បាប់ទាក់ទងនឹងការផ្តន្ទាទោសកុមារ និងការជួញដូរកុមារ

## ១.១ វត្ថុបំណង៖

បន្ទាប់ពីសិក្សាមេរៀននេះចប់គរុនិស្សិតនឹង៖

- កំណត់ពីភាពខុសគ្នានៃតម្រូវការ សិទ្ធិរបស់កុមារ
- ពន្យល់បានពីលក្ខណៈពិសេសនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ
- ពន្យល់ពីអត្ថន័យនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ
- ពិភាក្សាអំពីដំណើរការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

## ១.២ សេចក្តីផ្តើម៖

អនុសញ្ញាស្តីពីសិទ្ធិកុមារគឺជាកិច្ចព្រមព្រៀងមួយរបស់អ.ស.ប. ដែលបានកំណត់ពីសិទ្ធិរបស់កុមារ ហើយដែលកុមារនៅគ្រប់ទិសទីមានឱកាសទទួលបានសិទ្ធិទាំងនេះគ្រប់ៗគ្នា។ អនុសញ្ញានេះ កំណត់នូវបទដ្ឋានសម្រាប់សុខុមាលភាពកុមារ ទៅតាមដំណាក់កាលនានានៃការអភិវឌ្ឍរបស់កុមារ។ ចំណែកប្រទេសកម្ពុជាយើង បានផ្តល់សច្ចាប័នលើអនុសញ្ញានេះនៅថ្ងៃទី១៥ខែតុលាឆ្នាំ១៩៩២។

## ១.៣.១ តម្រូវការ និងសិទ្ធិ

### ក. តម្រូវការ

តម្រូវការគឺជាលក្ខខណ្ឌ នៃបញ្ហាមួយដែលកើតឡើងនៅពេលដែលមនុស្សម្នាក់ចង់បានអ្វីមួយយ៉ាងខ្លាំងក្នុងខណៈដែលខ្លួនមានកង្វល់ មានភាពតានតឹង មានបញ្ហាធ្ងន់ធ្ងរ ឬទីទ័លបំផុត។ តម្រូវការចាំបាច់មួយចំនួន គឺជាសិទ្ធិ ប៉ុន្តែសិទ្ធិមានព្រំដែន រីឯតម្រូវការគ្មានព្រំដែនទេ ហើយអាចប្រែប្រួលទៅតាមទីកន្លែង ស្ថានភាពសេដ្ឋកិច្ច និងពេលវេលា។ល។

### ខ. សិទ្ធិ

សិទ្ធិគឺជាអំពើដែលអាចធ្វើ និងមិនអាចធ្វើបាន នៅក្នុងក្របខណ្ឌមួយច្បាស់លាស់។ សិទ្ធិពាក់ព័ន្ធនឹងការសម្រេចចិត្តធ្វើសកម្មភាពអ្វីមួយប្រកបដោយភាពត្រឹមត្រូវ យុត្តិធម៌ និងសមធម៌ ដោយអនុលោមទៅតាមបែបបទ និងក្រឹត្យក្រមទាំងឡាយដែលមានចែងនៅក្នុងច្បាប់។

## ១.៣.២ តើអ្វីជាអនុសញ្ញាស្តីពីសិទ្ធិរបស់កុមារ?

អនុសញ្ញាស្តីពីសិទ្ធិកុមារគឺជាកិច្ចព្រមព្រៀងមួយរបស់អ.ស.ប. ដែលបានកំណត់ពីសិទ្ធិរបស់កុមារ ហើយដែលកុមារនៅគ្រប់ទិសទី មានឱកាសទទួលបានសិទ្ធិទាំងនេះគ្រប់ៗគ្នា។ អនុសញ្ញានេះកំណត់នូវបទដ្ឋានសម្រាប់សុខុមាលភាពកុមារ ទៅតាមដំណាក់កាលនានានៃការអភិវឌ្ឍរបស់កុមារ។ ចំណែកប្រទេសកម្ពុជាយើង បានផ្តល់សច្ចាប័នលើអនុសញ្ញានេះ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។

### ១.៣.៣ មូលហេតុនៃការបង្កើតអនុសញ្ញាស្តីពីសិទ្ធិកុមារ

- ដោយសារនៅក្នុងសង្គមជាច្រើនពុំទាន់មានច្បាប់ ឬរចនាសម្ព័ន្ធជាក់លាក់សម្រាប់ធានាដល់សិទ្ធិរបស់កុមារ។
- ដោយសារការអភិវឌ្ឍរបស់កុមារ គឺជាផ្នែកមួយដ៏សំខាន់បំផុត នៃអនាគតរបស់សង្គមជាតិនីមួយៗ
- ដោយសារតម្រូវការចាំបាច់ជាច្រើនរបស់កុមារពុំទាន់មានចែងនៅក្នុងឧបករណ៍សិទ្ធិមនុស្ស ដែលមានស្រាប់នៅឡើយ។
- ដោយសារផលប្រយោជន៍របស់កុមារមិនដូចគ្នានឹងផលប្រយោជន៍របស់អ្នកអាណាព្យាបាលរបស់កុមារ។
- ដោយសារកុមារងាយនឹងរងគ្រោះជាងមនុស្សចាស់នៅក្រោមលក្ខខណ្ឌការរស់នៅរបស់ខ្លួនហើយក៏ជាក្រុមដែលងាយទទួលរងគ្រោះ ជាពិសេសពីការកេងប្រវ័ញ្ច និងការរំលោភបំពានគ្រប់បែបយ៉ាង។
- ដោយសារកុមារពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការការពារខ្លួននៅចំពោះមុខច្បាប់។
- ដោយសារកុមារងាយនឹងទទួលផលប៉ះពាល់ជាងក្រុមអាយុផ្សេងៗទៀត។
- ដោយសារកុមារគ្មានសិទ្ធិបោះឆ្នោត ឬឥទ្ធិពលនយោបាយ ហើយមានកម្លាំងផ្នែកសេដ្ឋកិច្ច តិចតួចណាស់ដែលជាញឹកញាប់សំឡេងរបស់ពួកគេពុំត្រូវបានគេយកចិត្តទុកដាក់ស្តាប់ ឡើយ។
- ដោយសារនៅក្នុងសង្គមជាច្រើនតែងតែគិតថា កុមារគឺជាសម្បត្តិ ឬជាកម្មសិទ្ធិរបស់មាតាបិតា។ សង្គមខ្លះយល់ថាកុមារដូចមនុស្សធំអាចធ្វើការងារបាន ហើយខ្លះទៀតគិតថា ពួកគេមិនទាន់អាចចូលរួមជួយសង្គមបាននៅឡើយ។





- ដោយសារសង្គមជាតិនីមួយៗត្រូវមានកាតព្វកិច្ចបំពេញរាល់ សេចក្តីត្រូវការចាំបាច់របស់កុមារនិង ផ្តល់ការឧបត្ថម្ភលើការអភិវឌ្ឍកុមារ ទាំងបុគ្គលភាព ប្រាជ្ញា ស្មារតី និងសមត្ថភាព។

## ១.៣.៤ ដំណើរការបង្កើតអនុសញ្ញាស្តីពីសិទ្ធិកុមារ

- ឆ្នាំ១៩២៤សម្ព័ន្ធប្រជាជាតិបានអនុម័តលើសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិកុមារនៅទីក្រុងហ្សឺណែវ។ សេចក្តីប្រកាសនេះ បានគូសបញ្ជាក់អំពីកាតព្វកិច្ចរបស់មនុស្សគ្រប់រូបចំពោះកុមារ និងសង្កត់ធ្ងន់តម្រូវការការពារយ៉ាងពេញលេញ ដើម្បីសុខុមាលភាពរបស់កុមារ។
- ឆ្នាំ១៩៤៨ អ.ស.ប. បានអនុម័តលើសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស។ សេចក្តីថ្លែងការណ៍ ជាសកលស្តីពីសិទ្ធិមនុស្សនេះបានគ្របដណ្តប់លើសិទ្ធិកុមារដែរ តែមានប្រទេសជាច្រើនយល់ឃើញថា នៅតែពុំទាន់គ្រប់គ្រាន់នៅឡើយ ហើយគិតថា ត្រូវបន្ថែមសេចក្តីត្រូវការចាំបាច់ៗមួយទៀត ព្រមទាំងត្រូវធ្វើឱ្យឯកសារនោះមានលក្ខណៈពិសេសដាច់ពីគេទៀតផង។
- ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៥៩អ.ស.ប.បានអនុម័តលើសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិកុមារដែលក្នុងនោះមាន១០ចំណុច ព្រមទាំងរួមបញ្ចូលនូវគោលការណ៍ណែនាំពីការងារ ដើម្បីឧត្តមប្រយោជន៍កុមារ។
- ឆ្នាំ១៩៧៨ រដ្ឋាភិបាលប្រទេសប៉ូឡូញ បានដាក់សេចក្តីព្រាងអនុសញ្ញាស្តីពី សិទ្ធិកុមារជូនគណៈកម្មាធិការសិទ្ធិកុមាររបស់ អ.ស.ប.។ ឆ្នាំ១៩៧៩គណៈកម្មាធិការនេះបានបង្កើតក្រុមការងារមួយឱ្យគិតគូពិចារណាលើបញ្ហាអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ការងារនេះ ក៏ក្លាយជាការពិភាក្សាវែកញែកគ្នាអស់រយៈមួយទស្សវត្សរ៍អំពីគំនិតសំខាន់ៗនិងលក្ខណៈចាំបាច់នៃសិទ្ធិកុមារ។
- ការជជែកវែកគ្នានោះ មិនមែនគ្រាន់តែចូលរួមដោយតំណាងរដ្ឋាភិបាល អង្គការអន្តររដ្ឋាភិបាល ដូចជា អង្គការមូលនិធិសម្រាប់កុមារនៃអ.ស.ប. (យូនីសេហ្វ) ប៉ុណ្ណោះទេ ប៉ុន្តែក៏មានអង្គការមិនមែន រដ្ឋាភិបាលមួយចំនួនទៀតចូលរួមផងដែរ។
- ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ អ.ស.ប. បានអនុម័តលើអនុសញ្ញាស្តីពីសិទ្ធិកុមារ។
- នៅថ្ងៃទី០២ខែកញ្ញាឆ្នាំ១៩៩០អនុសញ្ញាស្តីពីសិទ្ធិកុមារ ត្រូវបានចូលជាធរមានទៅជាច្បាប់មួយរបស់អន្តរជាតិ បន្ទាប់ពីរដ្ឋចំនួន២០បានផ្តល់សច្ចាប័នរួចមក។
- ឆ្នាំ១៩៧៨ រដ្ឋាភិបាលប្រទេសប៉ូឡូញ បានដាក់សេចក្តីព្រាងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជូនគណៈកម្មាធិការសិទ្ធិកុមាររបស់ អ.ស.ប.។ ឆ្នាំ១៩៧៩គណៈកម្មាធិការនេះ បានបង្កើតក្រុមការងារមួយ ឱ្យគិតគូពិចារណាលើបញ្ហាអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ការងារនេះ ក៏ក្លាយជាការពិភាក្សាវែកញែក គ្នា អស់រយៈមួយទស្សវត្សរ៍ អំពីគំនិតសំខាន់ៗ និងលក្ខណៈចាំបាច់នៃសិទ្ធិកុមារ។
- ការជជែកវែកគ្នានោះ មិនមែនគ្រាន់តែចូលរួមដោយតំណាងរដ្ឋាភិបាល អង្គការអន្តររដ្ឋាភិបាល ដូចជា អង្គការមូលនិធិសម្រាប់កុមារនៃអ.ស.ប.(យូនីសេហ្វ) ប៉ុណ្ណោះទេ ប៉ុន្តែក៏មានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនទៀតចូលរួមផងដែរ។
- ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩អ.ស.ប. បានអនុម័តលើអនុសញ្ញាស្តីពីសិទ្ធិកុមារ។

- នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩០ អនុសញ្ញាស្តីពីសិទ្ធិកុមារ ត្រូវបានចូលជាធរមានទៅជាច្បាប់មួយរបស់អន្តរជាតិ បន្ទាប់ពីរដ្ឋចំនួន២០បានផ្តល់សច្ចាប័នរួចមក។

### កាលបរិច្ឆេទសំខាន់ៗនៃអនុសញ្ញាស្តីពីសិទ្ធិកុមារៈ

១៩២៤: សេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិកុមារត្រូវបានអនុម័តដោយសម្ព័ន្ធប្រជាជាតិ

១៩៤៨: មហាសន្និបាតនៃអ.ស.ប.អនុម័តសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស

១៩៥៩: អ.ស.ប.អនុម័តសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិកុមារ

១៩៧៩: ឆ្នាំអន្តរជាតិនៃកុមារ ក្រុមការងារមួយចំនួនបានបង្កើតឡើង ដើម្បីធ្វើសេចក្តីព្រាងអនុសញ្ញាស្តីពីសិទ្ធិកុមារ

១៩៨៩: អនុសញ្ញាស្តីពីសិទ្ធិកុមារត្រូវបានអនុម័តដោយមហាសន្និបាត អ.ស.ប. នៅថ្ងៃទី២០ ខែវិច្ឆិកា

១៩៩០: អនុសញ្ញាស្តីពីសិទ្ធិកុមារចូលជាធរមានជាច្បាប់អន្តរជាតិ នៅថ្ងៃទី០២ ខែកញ្ញា

### ១.៣.៥ អ្វីជាការផ្តល់សច្ចាប័ន ?

ការផ្តល់សច្ចាប័នមានន័យថា ជាការទទួលស្គាល់ជាផ្លូវការនិងយល់ព្រមទទួលយកមកអនុវត្ត ឬជាការប្តេជ្ញាចិត្តជាផ្លូវការរបស់រដ្ឋាភិបាលក្នុងការប្រតិបត្តិតាម។

ក្នុងករណីនេះមានន័យថា ប្រទេសដែលបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារមានកាតព្វកិច្ចពិនិត្យ មើលច្បាប់បែបបទផ្សេងៗ ដែលកំពុងតែអនុវត្តនៅក្នុងប្រទេសរបស់ខ្លួន ដោយធ្វើយ៉ាងណាឲ្យស្របតាមខ្លឹមសារនិងបទប្បញ្ញត្តិ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងបែងចែកធនធានដែលមាននៅក្នុងកម្រិតខ្ពស់បំផុតដែលអាចធ្វើបាន ដើម្បីធានានូវការអនុវត្តអនុសញ្ញានេះឲ្យមានប្រសិទ្ធភាពខ្ពស់។ ប្រទេសទាំងនោះមានកាតព្វកិច្ចធ្វើរបាយការណ៍មួយ អំពីស្ថានភាពនៃការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនេះទៅគណៈកម្មាធិការអង្គការសហប្រជាជាតិរយៈពេល២ឆ្នាំបន្ទាប់ពីថ្ងៃផ្តល់សច្ចាប័ន និងជាបន្តបន្ទាប់មកទៀតត្រូវធ្វើរបាយការណ៍រៀងរាល់ប្រាំឆ្នាំម្តង។ មកដល់បច្ចុប្បន្ននេះមានប្រទេសទាំងអស់ ចំនួន១៩៣ហើយ ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនេះ។ ប្រទេសកម្ពុជា បានផ្តល់ សច្ចាប័នទៅលើអនុសញ្ញានេះ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។

### ១.៣.៦ លក្ខណៈពិសេសនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

#### ក) ជាច្បាប់អន្តជាតិ

អនុសញ្ញាអ.ស.ប.ស្តីពីសិទ្ធិកុមារត្រូវបានអនុម័តដោយអង្គការសហប្រជាជាតិនៅ ថ្ងៃទី២០ វិច្ឆិកា ឆ្នាំ១៩៨៩។ អនុសញ្ញានេះ បានផ្សារភ្ជាប់កាតព្វកិច្ចខាងផ្លូវច្បាប់ ចំពោះរដ្ឋភាគីក្នុងការអនុវត្ត មានយន្តការតាមដាន ត្រួតពិនិត្យការអនុវត្តអនុសញ្ញានេះតាមរយៈការធ្វើរបាយការណ៍របស់ ប្រទេសជាភាគី។

#### ខ) មានលក្ខណៈទូលំទូលាយ

អនុសញ្ញាអ.ស.ប. ស្តីពីសិទ្ធិកុមារគឺជាឯកសារដែលបរិយាយពិស្តារអំពីសិទ្ធិទាំងឡាយរបស់កុមារ ដូចជា សិទ្ធិពលរដ្ឋ និងសេរីភាព គ្រួសារនិងការថែទាំ សុខភាព អប់រំ វប្បធម៌ វិធានការការពារ ផ្សេងៗ ។ល។

**គ)គ្មានលក្ខខណ្ឌ**

ប្រទេសដែលផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនេះ មានកម្រិតទទួលខុសត្រូវដូចគ្នាក្នុងការអនុវត្តសិទ្ធិកុមារមិនថា ជាប្រទេសកំពុងអភិវឌ្ឍ ឬប្រទេសឧស្សាហកម្មជឿនលឿនឡើយ។ ហើយអនុសញ្ញានេះមានសារៈសំខាន់ចំពោះកុមារគ្រប់រូប មិនថានៅទីណា ឬតំបន់ណាឡើយ។

**ឃ)អនុវត្តចំពោះកុមារទូទៅ**

អនុសញ្ញាស្តីពីសិទ្ធិកុមារ ត្រូវបានដាក់ឱ្យអនុវត្ត ចំពោះកុមារគ្រប់រូបដោយគ្មានការរើសអើងអ្វីឡើយ ឲ្យតែអ្នកនោះមានអាយុក្រោម១៨ឆ្នាំ។

## ១.៣.៧ មាត្រាស្តីពីទណ្ឌកម្មកុមារ និងការជួញដូរកុមារ

- ការដាក់ទណ្ឌកម្ម គឺជាសកម្មភាពមួយ ដែលគេធ្វើទៅលើបុគ្គលណាម្នាក់ ដែលល្មើសច្បាប់ឬប្រព្រឹត្តមិនសមរម្យ។ ការដាក់ទណ្ឌកម្ម មានគោលបំណង ដើម្បីត្រួតត្រាលើអាកប្បកិរិយាតាមរយៈមធ្យោបាយអវិជ្ជមាន។
- ការអប់រំវិន័យ គឺជាការបង្រៀនមនុស្ស (ការអប់រំទូន្មាន)ឱ្យចេះគោរពច្បាប់ ឬក្រមសីលធម៌ ក្នុងការសម្តែងអាកប្បកិរិយា ទាំងនៅក្នុងរយៈពេលខ្លីនិងរយៈ ពេលវែង។
- ការដាក់ទណ្ឌកម្មលើរាងកាយ គឺជាចេតនាធ្វើឱ្យមានការ ឈឺចាប់ផ្នែករាងកាយ ដែលជាធម្មតាធ្វើឡើងដើម្បីបញ្ឈប់អាកប្បកិរិយាមិនសមរម្យណាមួយ ដើម្បីពិន័យ ដើម្បីទប់ស្កាត់ការប្រព្រឹត្តកុំឱ្យកើតឡើងដដែលៗ។
- ការដាក់ទណ្ឌកម្មលើផ្លូវចិត្ត គឺធ្វើឡើងតាមរយៈ ការប្រើពាក្យសម្តីគំហក គំរាមកំហែង អាក្រក់គ្រោតគ្រាត គាបសង្កត់ មើលងាយ មើលថោក ជេរប្រមាតកាតទាន ឬដោយប្រើកាយវិការទ្រគោះបោះបោក មិនអើពើមិនយកចិត្តទុកដាក់...ជាដើម។

### ច្បាប់ពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្មលើកុមារ

- អនុសញ្ញាស្តីពីសិទ្ធិកុមារ ( មាត្រា១៩ និងមាត្រា៣៧ )
- ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ( មាត្រា៣១ និងមាត្រា៤៨ )
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល( មាត្រា៤១ និងមាត្រា៦៨ )
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ( មាត្រា២ និងមាត្រា៣ )
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ( មាត្រា១១៥ និងមាត្រា១១៦)
- សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡាលេខ៩២២អយក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៦

- ○ បទបញ្ញាផ្ទៃក្នុងរបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៩៦ ( ប្រការ៧ និងប្រការ២៥ )។

**(សូមអានក្នុងសៀវភៅ "*ឯកសារបង្រៀនពីការអនុវត្តសិទ្ធិកុមារក្នុងសាលារៀន*" ទំព័រ៤១៣-៤២២ )**

## ១.៤ សន្និដ្ឋាន

អនុសញ្ញាស្តីពីសិទ្ធិកុមារ គឺជាឯកសារដ៏មានសារៈសំខាន់ សម្រាប់កុមារទាំងអស់នៅលើពិភពលោក ដែលអាចជួយការពារកុមារ និងទប់ស្កាត់នូវរាល់ការរំលោភបំពានគ្រប់រូបភាពលើកុមារ ។

# សំណួរ

1. ហេតុអ្វីបានជាសិទ្ធិមានសារៈសំខាន់?
2. តើអនុញ្ញាស្តីពីសិទ្ធិកុមារជាអ្វី?
3. តើការផ្តល់សច្ចាប័នជាអ្វី?
4. តើអនុសញ្ញាស្តីពីសិទ្ធិកុមារមានលក្ខណៈពិសេសអ្វីខ្លះ?
5. តើការដាក់ទណ្ឌកម្មកុមារជាអ្វី?

# មេរៀនទី២
# អនុសញ្ញាស្តីពីសិទ្ធិកុមារ និងច្បាប់ទាក់ទងនឹងការផ្តន្ទាទោសកុមារ និងការជួញដូរកុមារ

## ២.១ វត្ថុបំណង

បន្ទាប់ពីសិក្សាមេរៀននេះចប់គរុនិស្សិតអាចៈ

- ពន្យល់ពីហានិភ័យនៃពេស្យាចារកុមារ
- កំណត់សញ្ញានៃការរំលោភបំពាន និងការជួញដូរកុមារ
- កំណត់វិធីក្នុងការការពារពួកគេចៀសពីការរំលោភបំពាន និងការជួញដូរកុមារ និងមានសមត្ថភាពដឹងពីសិទ្ធិរបស់ពួកគេក្នុងករណីរំលោភបំពាន និងជួញដូរ
- ធ្វើការរាយការណ៍ពីករណីនៃការរំលោភបំពាន និងការជួញដូរកុមារទៅកាន់អាជ្ញាធរពាក់ព័ន្ធ។

## ២.២ សេចក្តីផ្តើម

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់កំពូលរបស់ប្រទេស បានទទួលស្គាល់រាល់សិទ្ធិរបស់កុមារដូចដែលបានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ដូច្នេះគ្រប់ច្បាប់ទាំងអស់ត្រូវតែគោរពតាមអនុសញ្ញានេះ ។ ប៉ុន្តែបើមានច្បាប់ណាមួយមិនគោរពសិទ្ធិកុមារទេនោះ គឺមានន័យច្បាប់នោះមិនអនុលោមទៅតាមមាត្រា ១៥០-ថ្មី នៃរដ្ឋធម្មនុញ្ញឡើយ ។ មាត្រានៃរដ្ឋធម្មនុញ្ញដែលបានគាំទ្រ និងការពារសិទ្ធិរបស់កុមារ មានដូចជាមាត្រា៣១ ៤៦ ៤៧ និង៤៨ ។ ក្រៅពីនេះ នៅមានច្បាប់កម្ពុជាជាច្រើនទៀតដែលការពារផលប្រយោជន៍របស់កុមារ ដូចជាច្បាប់ការងារ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្សនិងអំពើធ្វើអាជីវកម្មលើមនុស្ស។ល។ *( ឯកសារបង្រៀនពីការអនុវត្តសិទ្ធិកុមារក្នុងសាលារៀន ទំព័រ ៣១ )*។

## ២.៣ ខ្លឹមសារ

### ២.៣.១ ពេស្យាចារលើកុមារ

- ជាការប្រើកុមារណាម្នាក់ក្នុងសកម្មភាពផ្លូវភេទ ដើម្បីរកផលប្រយោជន៍ឲ្យខ្លួន(មានការលក់ទិញសុទ្ធតែជាការខុសច្បាប់)។
- ហេតុអ្វីបានជាមានការលក់ពេស្យាចារកុមារ?(មានអ្នកត្រូវការទិញ-លក់ អ្នកឆោតល្ងង់ ក្រីក្រ អវិជ្ជា នឹងមានភ្ញៀវទេសចរណ៍...)។




- អ្នកណាត្រូវការរួមភេទ?(អ្នកមាន ភៀវទេសចរណ៍ ជនពាល អ្នកញៀនថ្នាំ...)។

## ២.៣.២.ការជួញដូរកុមារ

ការជួញដូរមនុស្សមានន័យថា ជាការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការសំចត ឬការទទួលយកមនុស្សដោយមធ្យោបាយគំរាមកំហែងឬប្រើកម្លាំងឬដោយទម្រង់ផ្សេងៗទៀតនៃការបង្ខាប់បញ្ជា ការចាប់ពង្រត់ ការក្លែងបន្លំ ការបោកបញ្ឆោត ការរំលោភបំពានដោយអំណាយ ឬការដាក់ឲ្យនៅ ក្នុងស្ថានភាពងាយឈឺ ឬការផ្តល់ ការទទួលប្រាក់សំណង ឬផលប្រយោជន៍ផ្សេងៗ ដើម្បីធ្វើឱ្យមានការ យល់ព្រមពីអ្នកគ្រប់គ្រងលើមនុស្សដទៃទៀតក្នុងគោបំណងកេងប្រវ័ញ្ច។ការជួញដូរកុមារគឺជាការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការចត ឬការទទួលកុមារ ក្នុងគោល បំណងធ្វើការកេងប្រវ័ញ្ច ទោះបីជាអំពើនេះមិនពាក់ព័ន្ធជាមួយនឹងមធ្យោបាយណាមួយ ដែលមានចែង ក្នុងវាក្យខ័ណ្ឌ(ក) នៃមាត្រានេះក៏ដោយ។

## ២.៣.៣ ការកេងប្រវ័ញ្ច

មានន័យថា មនុស្សម្នាក់ ឬច្រើននាក់ដែលមិនមែនជាជនរងគ្រោះ យកផលចំណេញពី ជនរងគ្រោះ។

- *ទម្រង់នានានៃការកេងប្រវ័ញ្ចៈ*
  - ការយកមនុស្សឲ្យធ្វើជាពេស្យាចារ
  - ការកេងប្រវ័ញ្ចផ្លូវភេទ
  - ការផលិតរូបភាពអាសអាភាស
  - ការបង្ខំឲ្យធ្វើពលកម្ម ឬសេវាកម្មនានា
  - ការយកមនុស្សមកធ្វើជាទេសករ ឬឲ្យធ្វើការងារទាំងឡាយណា ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងទាសករ ការយកសរីរាង្គណាមួយ។ល។

## ២.៣.៤ ការរំលោភបំពានផ្លូវភេទ

ការរំលោភបំពានផ្លូវភេទកុមារ គឺជាការរំលោភផ្លូវភេទ ការប៉ះពាល់ ឬការប្រព្រឹត្តអាកប្បកិរិយាទៅលើអនិតិជន ដែលធ្វើឲ្យគេមានអារម្មណ៍មិនល្អ ឬភ័យខ្លាច ។ ឧទាហរណ៍ពីការរំលោភបំពានផ្លូវភេទកុមារៈ

- ការប៉ះពាល់កេរ្តិ៍ភេទ ឬផ្នែកផ្សេងៗទៀតរបស់កុមារ
- ការបង្ហាញកេរ្តិ៍ភេទ ឬផ្នែកផ្សេងៗទៀតរបស់ជនដទៃដល់កុមារ
- ការឲ្យកុមារប៉ះពាល់កេរ្តិ៍ភេទ ឬផ្នែកផ្សេងៗទៀតរបស់ជនល្មើស ឬរបស់អ្នកដទៃ
- អំពើរួមភេទជាមួយកុមារ

- ការឲ្យកុមារមើលទស្សនាវដ្ដី ឬខ្សែភាពយន្តនានា ដែលបង្ហាញពីរូបភាពមនុស្សមានសម្លៀកបំពាក់តែបន្តិចបន្តួច ឬគ្មានសម្លៀកបំពាក់សោះ
- ការឱ្យកុមារថតរូបអាសអាភាសការនិយាយរឿងអាសអាភាស ឬរឿងកំប្លែងស្មោកគ្រោកប្រាប់កុមារ។ល។

### ២.៣.៥ រូបភាពអាសអាភាស ផ្លូវភេទប្រើប្រាស់នៅលើកុមារ

- សំដៅលើខ្លឹមសារទាំងឡាយណាដែលពណ៌នាអំពីសកម្មភាពផ្លូវភេទដែលពាក់ព័ន្ធនឹងកុមារ ។ រូបភាពដែលមើលឃើញរួមមានរូបថត វីដេអូឌីជីថល ឬរូបភាពដែលបង្កើតដោយកុំព្យូទ័រដែលមិនអាចបែងចែកបានពីអនីតិជនពិតប្រាកដ។
  រូបភាពនិងវីដេអូទាំងនេះពាក់ព័ន្ធនឹងឯកសារនៃកន្លែងកើតហេតុឧក្រិដ្ឋកម្មជាក់ស្តែងត្រូវបានផ្សព្វផ្សាយសម្រាប់ការប្រើប្រាស់។
- ការបង្ហាញរូបភាពណាមួយរួមទាំងរូបថត ខ្សែភាពយន្ត វីដេអូ រូបភាព ឬរូបភាពដែលបង្កើតដោយកុំព្យូទ័រ ឬមធ្យោបាយផ្សេងទៀតនៃអាកប្បកិរិយាផ្លូវភេទ។

## ២.៤ សន្និដ្ឋាន

ប្រទេសកម្ពុជាយើងមានច្បាប់សមល្មម ដែលអាចឲ្យយើងលុបបំបាត់ការជួញដូរ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារបាន។ អ្វីដែលយើងទាំងអស់គ្នា ត្រូវខិតខំបន្តធ្វើទាំងអស់គ្នា គឺការពង្រឹកការអនុវត្តច្បាប់ ។ គ្មាននរណាម្នាក់អាចរស់នៅលើច្បាប់បាន ហើយដើម្បីអនុវត្តច្បាប់ឲ្យកាន់តែមានប្រសិទ្ធភាព គឺត្រូវចាប់ផ្ដើមពីបុគ្គលយើងម្នាក់ៗ។ ប្រសិនបើយើងម្នាក់ៗ គោរពច្បាប់ទាំងអស់គ្នា នោះនឹងគ្មានអំពើរំលោភបំពានកើតមានទេ ។

# សំណួរ

1. តើពេស្យាចារកុមារជាអ្វី?
2. តើអ្នកណាអាចធ្វើការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ?
3. ដូចម្តេចដែលហៅថាការជួញដូរ ការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទ?
4. តើសកម្មភាពអ្វីខ្លះដែលគេចាត់ទុកថាជាការរំលោភបំពានផ្លូវភេទកុមារ?តើអ្នកត្រូវធ្វើដូចម្តេចនៅពេលអ្នកឃើញមានការរំលោភបំពាន ឬជួញដូរលើកុមារ?
5. តើសកម្មភាពអ្វីខ្លះដែលគេចាត់ទុកថាជាការរំលោភបំពានផ្លូវភេទកុមារ?តើអ្នកត្រូវធ្វើដូចម្តេចនៅពេលអ្នកឃើញមានការរំលោភបំពាន ឬជួញដូរលើកុមារ?

# មេរៀនទី៣៖
# វិធីដែលកុមារអាចប្រើដើម្បីការពារខ្លួន និងមិត្តភក្តិ ពីការរំលោភផ្លូវភេទ

## ៣.១ វត្ថុបំណង

ក្រោយពីបញ្ចប់ការសិក្សាអំពីមេរៀននេះ គរុនិស្សិតអាច៖

- យល់ដឹងពីវិធីមួយចំនួន ដើម្បីចូលរួមជួយការពារសិស្សពីការរំលោភបំពានផ្លូវភេទ
- យកខ្លឹមសារមេរៀននេះ ទៅបង្រៀនដល់សិស្ស ដើម្បីឱ្យពួកគេអាចមានលទ្ធភាពការពារខ្លួន ។

## ៣.២ សេចក្តីផ្តើម

នៅក្នុងសង្គមជាតិនីមួយៗ តែងតែមានមនុស្សល្អ និងមនុស្សអាក្រក់ ។ មនុស្សល្អជាអ្នកខិតខំស្វែងរកឧត្តមប្រយោជន៍ និងគុណតម្លៃ សម្រាប់ជីវិតផ្ទាល់ខ្លួន និងសង្គមទាំងមូល ។ ចំណែកឯពពួកមនុស្សអាក្រក់ គឺធ្វើអ្វីៗ មានភាពផ្ទុយពីមនុស្សល្អទាំងស្រុង ។ ពួកគេបំផ្លាញផលប្រយោជន៍ សេចក្តីសុខ និងកិត្តិយសអ្នកដទៃ ឬសង្គមដើម្បីតែការរស់នៅបែបពាលារបស់ពួកគេប៉ុណ្ណោះ ។ ជនខិលខូចមានច្រើនប្រភេទ ពួកគេប្រព្រឹត្តអំពើអាក្រក់ តាមជំនាញរបស់ក្រុមគេនីមួយៗ ដូចជា ក្រុមលួច ក្រុមឆក់ក្រុមប្លន់ ក្រុមឆបោក ក្រុមប្រើល្បិចលួងលោមបោកប្រាស់មនុស្ស ដើម្បីយកទៅបម្រើគោលបំណងផ្សេងៗ។ល។ ប៉ុន្តែក្នុងមេរៀននេះ គឺលើកយកវិធីមួយចំនួន ដែលកុមារអាចប្រើដើម្បីការពារខ្លួន និងមិត្តភក្តិពីការរំលោភផ្លូវភេទ ។

## ៣.៣ ខ្លឹមសារ

### ៣.៣.១ វិធីដែលកុមារអាចប្រើ

ចំណុចមួយចំនួនដែលកុមារត្រូវចងចាំ និងយកមកប្រើប្រាស់ នៅពេលដែលខ្លួនឯងផ្ទាល់ ឬមិត្តភក្តិ ជួបបញ្ហា៖

❖ **កុមារមានសិទ្ធិនិយាយបដិសេធថា “ ទេ ”**

កុមារមានសិទ្ធិនិយាយបដិសេធថា **“ទេ”** ចំពោះជនណា ដែលព្យាយាមប៉ះពាល់រាងកាយកុមារ ដែលធ្វើឱ្យកុមារមានអារម្មណ៍មិនល្អ ឬភ័យខ្លាច ។

❖ **កុមារមិនគួរជឿរឿងអាថ៌កំបាំងមួយចំនួនទេ**

មានរឿងសម្ងាត់ខ្លះ កុមារមិនគួរលាក់បាំងទេ ទោះបីជា កុមារបានសន្យាថា មិននិយាយប្រាប់អ្នកណាក៏ដោយ ។

ជារឿយៗមនុស្សដែលប្រព្រឹត្តអំពើអាក្រក់លើកុមារ តែងប្រាប់កុមារថា កុំឲ្យនិយាយពីអ្វីដែលបានកើតឡើងប្រាប់អ្នកដទៃ ។ ពួកគេដឹងខ្លួនថាគេបានធ្វើខុស ដោយភ័យខ្លាចការទទួលទណ្ឌកម្ម ។

ការឱប និងការថើប ជាកាយវិការល្អប្រពៃជាពិសេសពីមនុស្សជិតស្និទ្ធ និងទុកចិត្ត ។ ក៏ប៉ុន្តែមិនត្រូវឲ្យនរណាម្នាក់សុំថើប សុំឱប ឬប៉ះពាល់កន្លែងសម្ងាត់នៃរាងកាយទេ ។ មនុស្សពេញវ័យអាច

និយាយថា *"វាមិនមែនជាកន្លែង សម្ងាត់ជំជុំអីទេ"* ។ ប្រសិនបើមាននរណាម្នាក់ និយាយដូច្នោះទៅកាន់កុមារ ទោះបីកុមារស្គាល់អ្នកនោះក៏ដោយ ក៏កុមារត្រូវនិយាយរឿងនេះប្រាប់មនុស្សពេញវ័យណាដែលកុមារទុកចិត្ត ។

❖ **កុមារមិនត្រូវឲ្យគេប៉ះពាល់រាងកាយដោយផ្ដេសផ្ដាសឡើយ**

កុមារមិនត្រូវឲ្យនរណាម្នាក់ប៉ះពាល់រាងកាយ តាមរបៀបមួយដែលធ្វើឲ្យកុមារមានអារម្មណ៍មិនល្អ ឬភ័យខ្លាច ។ កុមារក៏មិនត្រូវប៉ះពាល់រាងកាយកុមារដទៃ ដែលធ្វើឲ្យគេមានអារម្មណ៍មិនល្អ ឬភ័យខ្លាចដែរ។ កុមារត្រូវសួរមនុស្សពេញវ័យណា ដែលខ្លួនទុកចិត្តនៅពេលណាដែលកុមារមានភាពមិនច្បាស់លាស់អំពីការប៉ះពាល់ ឬអាកប្បកិរិយារបស់អ្នកណាម្នាក់មកលើខ្លួន ។

❖ **កុមារត្រូវរត់គេចចេញ**

ប្រសិនបើមានមនុស្សចម្លែក ឬនរណាម្នាក់ដែលកុមារធ្លាប់ស្គាល់ ព្យាយាមធ្វើអំពើមិនល្អ ឬមិនគប្បីមកកាន់ខ្លួន កុមារត្រូវរត់ចេញពីជនទាំងនោះ និងស្វែងរកជំនួយ ហើយចាំថាត្រូវរត់ទៅរកទីកន្លែងណាដែលមានមនុស្សច្រើន ។

❖ **កុមារត្រូវស្រែកឱ្យខ្លាំងៗ**

កុមារអាចស្រែកបាន ប្រសិនបើ មាននរណាម្នាក់កំពុងព្យាយាមធ្វើបាបខ្លួន ។ កុមារមិនត្រូវស្ទាក់ស្ទើរក្នុងការស្រែក ឬហៅរកជំនួយឡើយ នៅពេលដែលខ្លួន ឬមិត្តភក្ដិកំពុងប្រឈមនឹងបញ្ហា ។

❖ **កុមារមិនត្រូវទទួលយកអំណោយរបស់គេឡើយ**

កុមារមិនត្រូវទទួលយកស្ករគ្រាប់ លុយកាក់ ឬកាដូពីនរណាម្នាក់ ដោយមិនបាននិយាយប្រាប់ឪពុកម្ដាយ ឬអ្នកដែលមើលថែទាំខ្លួនឡើយ ។ វាមិនជាបញ្ហាទេ កុមារអាចទទួលកាដូពីមិត្តភក្ដិ និងក្រុមគ្រួសារ ។ ក៏ប៉ុន្តែមានមនុស្សពេញវ័យដែលកុមារស្គាល់ និងទុកចិត្តខ្លះ អាចឲ្យកាដូរ និងលុយកាក់ ដើម្បីបោកបញ្ឆោតកុមារឲ្យធ្លាក់ក្នុងទង្វើមិនល្អដែរ ។

❖ **កុមារត្រូវនិយាយរឿងប្រាប់អ្នកណាម្នាក់**

ប្រសិនបើ កុមារទទួលរងនូវការរំលោភបំពាននានា កុមារត្រូវនិយាយរឿងប្រាប់មិត្តភក្ដិ ប្រាប់គ្រូបង្រៀន ប្រាប់ឪពុកម្ដាយ ឬមនុស្សពេញវ័យណា ដែលខ្លួនទុកចិត្ត ។ វាអាចជាការពិបាកសម្រាប់កុមារក្នុងការនិយាយរឿងបែបនេះប្រាប់គេ ។ ប្រសិនបើកុមារមានអារម្មណ៍ថា មិនអាចនិយាយបាន ព្យាយាមសរសេរពន្យល់ប្រាប់ពីអារម្មណ៍របស់ខ្លួនទៅឪពុក ឬម្ដាយ ។ ប្រសិនបើកុមារមានការពិបាកក្នុងការនិយាយទៅកាន់ម្ដាយ និងឪពុក អំពីរឿងរំលោភបំពាននោះ កុមារអាចនិយាយប្រាប់នរណាម្នាក់ដែលកុមារទុកចិត្ត ។ ប្រសិនបើឪពុក ឬម្ដាយ ឬគ្រូបង្រៀនជាអ្នករំលោភ កុមារអាចនិយាយប្រាប់រឿងនេះដល់នរណាម្នាក់ដែលកុមារទុកចិត្ត ដូចជាយាយ តា អ៊ំ មីង ពូ បងប្អូនជីដូនមួយ ឬអ្នកជិតខាង ។

❖ **កុមារត្រូវស្វែងយល់អំពីការរំលោភបំពាននានា**

កុមារត្រូវសិក្សាស្វែងយល់អំពីការរំលោភបំពាននានា ដោយត្រូវសួរនាំគ្រូបង្រៀន មិត្តភក្ដិ ឬមនុស្សពេញវ័យដទៃៗទៀត ដែលទុកចិត្ត ឬស្រាវជ្រាវពីបណ្ណាល័យ ។

❖ កុមារត្រូវហៅទូរស័ព្ទរកជំនួយ

ទោះបីជាពាក្យថា "ជំនាញសតវត្សរ៍ទី២១" អាចស្តាប់ទៅទំនើបក៏ដោយ ទាំងនេះជំនាញគឺ «មិនមែនជារឿងថ្មីទេ គ្រាន់តែសំខាន់ប៉ុណ្ណោះ» (Silva 2009, p. 631) ។ សមត្ថភាពសំខាន់ ដូចជាការគិតស៊ីជម្រៅ និងការដោះស្រាយបញ្ហា តែងតែមានសារៈសំខាន់ ។ ទោះយ៉ាងណាក៏ដោយ នាពេលបច្ចុប្បន្ននេះ ដោយសារតែតម្រូវការដែលកំពុងរីកចម្រើននៃសេដ្ឋកិច្ចផ្អែកលើចំណេះដឹង សមត្ថភាពទទួលបានសារៈសំខាន់កើនឡើង (Levy and Murnane 2004; Rotherham និង Willingham 2009)។ ដូចដែលបានលើកឡើងរួចមកហើយ វាមានជំនាញច្បាស់លាស់ ដ៏មានសារៈសំខាន់នៅក្នុងយុគសម័យព័ត៌មាន ដែលយើងកំពុងរស់នៅ ។ ឧទាហរណ៍ OECD (2004) និង Pedró (2006) យល់ឃើញថា ដោយសារការរីកចម្រើននៃព័ត៌មាន មាតិកាណាមួយ អាចលែងប្រើក្នុងរយៈពេលពីរបីឆ្នាំ ។ ការធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់គឺជាវិធីតែមួយគត់ដើម្បីបំពេញតាមតម្រូវការនៃសតវត្សរ៍ទី២១ ។ វាជាការសមរម្យដែលអ្នករាល់គ្នាត្រូវការ ដើម្បីត្រៀមខ្លួនសម្រាប់ និងជឿជាក់លើតម្រូវការដើម្បីក្លាយជាអ្នកសិក្សាពេញមួយជីវិត ដើម្បីរក្សាល្បឿន ជាមួយនឹងការវិវត្តន៍នៃបច្ចេកវិទ្យា (Medel-Añonuevo et al. 2001) ។

របាយការណ៍ Delors របស់ UNESCO (1996) ចេញផ្សាយដោយគណៈកម្មការអន្តរជាតិស្តីពីការអប់រំសម្រាប់សតវត្សរ៍ទី២១ បានវិភាគនិន្នាការនៃការអភិវឌ្ឍន៍ សតវត្សរ៍ ហើយសន្និដ្ឋានថា ការបន្តការអប់រំនឹងខុសគ្នាឆ្ងាយជាងការអប់រំក្នុងឆ្នាំ 1996 ។ ការទទួលស្គាល់នូវភាពច្បាស់លាស់នៃការបន្តការអប់រំនៅក្នុងសតវត្សរ៍ទី២១ UNESCO បានផ្តល់អនុសាសន៍ថាការអប់រំមានសសរស្តម្ភសំខាន់ៗចំនួនបួន៖ រៀនដើម្បីចំណេះដឹង រៀនដើម្បីចំណេះធ្វើ រៀនដើម្បីក្លាយជាពលរដ្ឋល្អ និងរៀនរស់នៅជាមួយគ្នា ដោយសុខសន្តិភាព។ សសរស្តម្ភទាំងបួននេះបានរួមចំណែកដល់ការយល់ឃើញនៃការរៀនសូត្រពេញមួយជីវិត

ដែលត្រូវបានកំណត់ជា «ការទាញយកប្រយោជន៍ពីគ្រប់ឱកាសដែលសង្គមផ្តល់ឱ្យ» (ទំព័រ ៣៨)។ ក្របខ័ណ្ឌទាំងអស់នេះ បង្ហាញដោយរបាយការណ៍ Delors របស់អង្គការយូណេស្កូ គឺជាប្រភេទទី១ ដែលដាក់បញ្ជូនបន្តក្នុងមុខងារអប់រំស្នូលនៅក្នុងសតវត្សរ៍ទី២១ និងក្របខ័ណ្ឌជាច្រើនទៀត ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ដើម្បីណែនាំពីរបៀបដែលការអប់រំគួរត្រូវសម្របតាមតម្រូវការដែលទើបនឹងកើតឡើងដោយបច្ចេកវិទ្យាដែលមានល្បឿនលឿន វឌ្ឍនភាពនៅក្នុងសេដ្ឋកិច្ចផ្អែកលើចំណេះដឹង (Enright 2000) ។ ជិតពីរទសវត្សរ៍ក្រោយ យូណេស្កូបានពិនិត្យបញ្ហានេះឡើងវិញ ដោយលើកបញ្ហានេះមកពិនិត្យអង្កេតពីរបៀបដែលសសរស្តម្ភទាំងបួននៃការអប់រំcation (របៀបដែលហៅថាសមត្ថភាពឆ្លងកាត់) (UNESCO 2015) ត្រូវបានអប់រំនៅក្នុងសាលារៀន។ជាមួយនឹងគោលបំណងពង្រឹងការយល់ដឹងរបស់មនុស្សម្នាក់ឆ្ពោះទៅរកសតវត្សរ៍ទី២១។ ជំនាញ ក្របខ័ណ្ឌជាច្រើនត្រូវបានបង្កើតឡើងក្រោមការជួយជ្រោមជ្រែងពីអន្តរជាតិ អង្គការ រដ្ឋាភិបាល និងក្រុមហ៊ុនប្រឹក្សាយោបល់ ។ ក្នុងចំណោមជួរដ៏ធំនៃក្របខ័ណ្ឌបីក្នុងចំណោមពួកគេត្រូវបានជ្រើសរើសដើម្បីបង្ហាញពីការលេចឡើងនៃមេគំនិត និងគំនិត។ ក្របខ័ណ្ឌទាំងបីត្រូវបានជ្រើសរើសដោយផ្អែកលើមូលដ្ឋានរបស់ពួកគេ។ ប្រភពដើមភូមិសាស្ត្រ និងធម្មជាតិនៃស្ថាប័នផ្តល់មូលនិធិរបស់ពួកគេ ។ គេសង្ឃឹមថាទាំងនេះ ក្របខ័ណ្ឌនឹងតំណាងឱ្យទស្សនៈផ្សេងគ្នាដែលអ្នកទទួល រី រ៉េមីនី Remini - AI Photo Enhancerជំនាញសតវត្សរ៍ទី២១ដំបូង និងផែនទីបង្ហាញផ្លូវនៃការអប់រំសកល ១៨ វាមានតម្រូវការខ្លាំងជាងនេះសម្រាប់វិធីសាស្ត្រលម្អិត និងស្រាវជ្រាវយ៉ាងល្អដើម្បី ណែនាំអ្នកអប់រំ អ្នកគ្រប់គ្រងសាលា និងអ្នកបង្កើតគោលនយោបាយតាមរយៈ ដំណើរការដ៏ស្មុគស្មាញនៃការអនុវត្តការអប់រំជំនាញសតវត្សរ៍ទី២១ ។

វាសមហេតុផលដែលមនុស្សគ្រប់រូបត្រូវត្រៀមខ្លួនសម្រាប់ និងជឿជាក់លើតម្រូវការដើម្បីក្លាយជាអ្នកសិក្សាពេញមួយជីវិត ដើម្បីរក្សាល្បឿន ជាមួយនឹងការវិវត្ត នៃបច្ចេកវិទ្យា (Medel-Añonuevo et al. 2001)។ របាយការណ៍ Delors របស់អង្គការយូណេស្កូ (1996) ចេញដោយគណៈកម្មការអន្តរជាតិស្តីពីការអប់រំសម្រាប់សតវត្សរ៍ទី២១ បានវិភាគនិន្នាការ នៃការអភិវឌ្ឍន៍នៃសតវត្សរ៍ ហើយបានសន្និដ្ឋានថាការបន្តការអប់រំនឹងលើសពីអ្វីដែលវាមាននៅក្នុងឆ្នាំ1996។ ខណៈពេលដែលក្របខ័ណ្ឌនេះ បង្ហាញដោយរបាយការណ៍ Delors របស់អង្គការយូណេស្កូ គឺជាប្រភេទទីមួយដែលដាក់ឱ្យដំណើរការមុខងារអប់រំស្នូលក្នុងសតវត្សទី២០នោះ ក្របខ័ណ្ឌផ្សេងទៀតជាច្រើនត្រូវបានបង្កើតឡើង ជាបន្តបន្ទាប់ដើម្បីណែនាំពីរបៀបដែលការអប់រំគួរតែត្រូវបានសម្របខ្លួនដើម្បីបំពេញតាមតម្រូវការ ដែលទើបនឹងកើតដែលបង្កឡើងដោយវឌ្ឍនភាពបច្ចេកវិទ្យាដែលមានល្បឿនលឿននៅក្នុងសេដ្ឋកិច្ចផ្អែកលើចំណេះដឹង(Enright 2000)។ ក្នុងចំណោមក្របខ័ណ្ឌដ៏ច្រើននេះ គេជ្រើសរើសចំនួនបីដើម្បីបង្ហាញពីការកើតឡើងនៃគំនិត និងសញ្ញាណសំខាន់ៗ។ ក្របខ័ណ្ឌទាំងបីត្រូវបានជ្រើសរើសដោយឈរលើមូលដ្ឋាននៃប្រភពដើមនៃភូមិសាស្ត្រ និងធម្មជាតិនៃស្ថាប័នផ្តល់មូលនិធិរបស់ ពួកគេ។ គេសង្ឃឹមថា ក្របខណ្ឌទាំងនេះនឹងតំណាងឱ្យទស្សនវិស័យផ្សេងៗគ្នាដែលខ្លួនមាន។

2.2 ជំនាញសតវត្សរ៍ទី២០ដំបូងក្នុងការប្រៀបធៀប ដោយប្រើវិធីសាស្ត្រស្រដៀងគ្នាដែលបាន អនុម័តដោយ Dede (2009) ដែលបានយកក្របខ័ណ្ឌ P21 ជាមូលដ្ឋានសម្រាប់ការវិភាគប្រៀបធៀប នៃក្របខ័ណ្ឌសតវត្សរ៍ទី២១ ផ្សេងៗ ដោយសារតែការគ្របដណ្តប់លម្អិតនៃសំណុំជំនាញ និងការសម្រប ខ្លួនយ៉ាងទូលំទូលាយ យើងព្យាយាមស្វែងយល់ពីភាពស្រដៀងគ្នាក្នុងក្របខ័ណ្ឌផ្សេងៗគ្នា។ ហើយដាក់ គំនិតត្រួតស៊ីគ្នា និងដូចគ្នា ដើម្បីផ្តល់ឱ្យអ្នកអាននូវវិធីងាយស្រួលក្នុងការយល់ដឹងអំពីគំនិត ស្នូលនៅក្នុង ក្របខ័ណ្ឌទាំងនេះ។

សមត្ថភាពសម្រាប់សំណុំនីមួយៗ នៃជំនាញសតវត្សរ៍ទី២១ (កែសម្រួលពី P21 2009) 3 សំណុំជំនាញ ការរៀនសូត្រ និងការច្នៃប្រឌិត អក្ខរកម្មឌីជីថល ជំនាញជីវិត និងអាជីព មុខវិជ្ជាស្នូល 12 សមាសជាតុ អក្ខរកម្ម ព័ត៌មាន ភាពបត់បែននិង ការត្រិះរិះពិចារណា និង អាជាប់ធ័រ ដោះស្រាយបញ្ហា អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ គំនិតផ្តួចផ្តើមនិង ការទំនាក់ទំនង និង ការសហការ ព័ត៌មាន និង ទំនាក់ទំនង ទិសដៅខ្លួនឯង សង្គម និងភាពច្នៃប្រឌិត និង អក្ខរកម្មបច្ចេកវិទ្យា ឆ្លងវប្បធម៌ ការច្នៃប្រឌិត អន្តរកម្ម ផលិតភាព និង គណនេយ្យភាព ភាពជាអ្នកដឹកនាំ និង ការទទួលខុសត្រូវ។

ជំនាញសតវត្សរ៍ទី២១ និងផែនទីបង្ហាញផ្លូវនៃការអប់រំសកល ២២

សំណុំជំនាញទី 1៖ ការរៀនសូត្រ និងការច្នៃប្រឌិត សំណុំជំនាញនៃការរៀនសូត្រនិងការបង្កើតថ្មី រួមបញ្ចូលផ្នែកសំខាន់ចំនួនបួនដែលគ្របដណ្តប់ ទាំងចំណេះដឹងនិងជំនាញទាក់ទងនឹងការសិក្សា។ "មុខវិជ្ជាស្នូល" ចង្អុលទៅចំណេះដឹងមុខ វិជ្ជាស្នូលដែលមិនអាចខ្វះបានសម្រាប់អ្នកសិក្សាទាំងអស់ ក្នុងសតវត្សរ៍ទី២១ដែលអាចសង្ខេប មិនច្បាស់លាស់ដោយអក្សរ "Rs" ចំនួនបីគឺ ការអាន ការសរសេរ និង aRithemetic។ ស្លាកសញ្ញានៃមុខវិជ្ជានេះមានភាពខុសប្លែកគ្នានៅទូទាំងទ្វីបផ្សេងៗគ្នានៃពិភពលោក ប៉ុន្តែចំណេះដឹងដែលគ្របដណ្តប់ដោយពួកគេគឺស្រដៀងគ្នានៅក្នុងខ្លឹមសារ ដែលគ្របដណ្តប់លើចំណេះ ដឹង ផ្នែកភាសា សោភ័ណភាព វិទ្យាសាស្ត្រ គណិតវិទ្យា មនុស្សសាស្ត្រ និងពលរដ្ឋ។ បន្ថែមពីលើចំណេះដឹងលើមុខវិជ្ជា ជំនាញសិក្សាមួយចំនួនត្រូវបានចាត់ទុកថាចាំបាច់ ជាពិសេសនៅក្នុង សតវត្សរ៍ទី២១។ ទាំងនេះរួមមានជំនាញការគិតពិចារណា និងការដោះស្រាយបញ្ហា ជំនាញទំនាក់ទំនង និងសហការគ្នា និងភាពច្នៃប្រឌិត និងការបង្កើតថ្មី។ ជំនាញទន់ទាំងនេះគឺជាចំណុចសំខាន់សម្រាប់ អ្នកសិក្សាដើម្បីទប់ទល់នឹងសង្គមដែលកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ដែលទំនាក់ទំនងរបស់មនុស្សជុំវិញ ពិភពលោក និងបរិមាណ និងលទ្ធភាព ទទួលបានព័ត៌មានត្រូវបានពង្រីកជាអតិបរមាដោយការរីកចម្រើន នៃបច្ចេកវិទ្យា។

សំណុំជំនាញទី2៖ អក្ខរកម្មឌីជីថល អក្ខរកម្មឌីជីថលត្រូវបានបង្កើតឡើងដោយ ជាតុផ្សំសំខាន់ៗ ចំនួនបី៖ ចំណេះដឹងផ្នែកព័ត៌មាន (IL) ជំនាញបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) និង ចំណេះដឹងប្រព័ន្ធផ្សព្វផ្សាយ (ML)។ IL គឺជាសមត្ថភាពក្នុងការជ្រើសរើស វាយតម្លៃ និងប្រើប្រាស់ ព័ត៌មានប្រកបដោយប្រសិទ្ធភាព និងត្រឹមត្រូវដើម្បីទទួលបានអនុវត្ត និងចែករំលែកចំណេះដឹងរបស់ ពួកគេ (American Association of School Librarians [AASL] 2007)។ ជំនាញ ICT

ដូចដែលបានកំណត់ដោយ International ICT Literacy Panel (2002) សំដៅលើសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យា ឌីជីថល ឧបករណ៍ទំនាក់ទំនង និង/ឬបណ្តាញដើម្បីចូលប្រើ គ្រប់គ្រង រួមបញ្ចូល វាយតម្លៃ និងបង្កើត អង្គភាពព័ត៌មាន។ សមាសភាគទីបី ML ដែលជាអន្តរកម្មសិក្សានៅក្នុងធម្មជាតិត្រូវបានផ្សារភ្ជាប់ ជាមួយនឹងសមត្ថភាពក្នុងការចូលប្រើ វិភាគ វាយតម្លៃ និងទំនាក់ទំនងសារក្នុងទម្រង់ផ្សេងៗ គ្នា (NAMLE 2012)។ នៅសតវត្សរ៍ទី 21 ព័ត៌មានអនឡាញអាចរកបានយ៉ាងងាយស្រួល។ ជីវិតមនុស្សបានភ្ជាប់ អ៊ីនធឺណិតកាន់តែជិតស្និទ្ធ និងពឹងផ្អែកខ្លាំងលើបច្ចេកវិទ្យាឌីជីថល។ សកម្មភាពក្នុងថ្នាក់រៀនកាន់តែច្រើនឡើងឥឡូវនេះគឺផ្អែកលើកុំព្យូទ័រ ហើយប្រើប្រាស់ លើភាពងាយស្រួលដែលនាំមកដោយ World Wide Web ។ ដូច្នេះ វាបានក្លាយជា រឿងសំខាន់សម្រាប់អ្នកសិក្សាក្នុងការទទួលបានចំណេះដឹង និងជំនាញដើម្បីទាញ យកថាមពល នៃបច្ចេកវិទ្យាឌីជីថល ក្នុងការពង្រីកឱកាសរបស់ពួកគេសម្រាប់ការរៀន ទំនាក់ទំនង ការសហការ និងការបង្កើតចំណេះដឹង (Trilling and Fadel 2009)។ ជាពិសេស នៅពេលដែលអ្នកសិក្សាត្រូវបានផ្តល់ឱ្យនូវឱកាសសិក្សាការសាកសួរ វាជារឿងសំខាន់ សម្រាប់ពួកគេដើម្បីឱ្យមានជំនាញ IL ដែលត្រូវការដើម្បីប្រមូលព័ត៌មានដែលពួកគេត្រូវការសម្រាប់សកម្មភាពស្រាវជ្រាវបន្ថែមទៀត ដែលជាការរួមចំណែកដល់ការស្ទាត់ជំនាញ និងការកសាងចំណេះដឹង ដោយជោគជ័យរបស់ពួកគេ (Todd 2008)។ លើសពីនេះទៅទៀត ជំនាញ ICT អាចឱ្យអ្នកសិក្សាប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាក្នុងដំណើរការសិក្សារបស់ពួកគេ។ ឧទាហរណ៍ សិស្ស (ជាពិសេស ក្មេងៗ) អាចត្រូវការជំនាញក្នុងការប្រើប្រាស់ MS Excel និង PowerPoint ដើម្បីបង្ហាញលទ្ធផលគម្រោងរបស់ពួកគេ។ ភាពលេចធ្លោស្មើគ្នាគឺ ML ដែលអនុញ្ញាតឱ្យអ្នកសិក្សាជំនាញសតវត្សរ៍ទី២០ដំបូងដោយលំអិត តារាង 2.3 និយមន័យប្រតិបត្តិការនៃជាតុផ្សំនៃអក្ខរកម្មឌីជីថល ឧទាហរណ៍ និយមន័យ សមាសភាគ ស្វែងរកព័ត៌មានតាមរយៈអ៊ីនធឺណិត ឬប្រភពផ្សេងទៀត (ឧ. សៀវភៅ កាសែត ទូរទស្សន៍ យូធូប) សមត្ថភាពក្នុងការទទួលស្គាល់នៅពេលណា អក្ខរកម្មព័ត៌មាន (IL) ព័ត៌មានគឺចាំបាច់ និងសមត្ថភាព ក្នុងការកំណត់ទីតាំង វាយតម្លៃ និងប្រើប្រាស់ព័ត៌មានប្រកបដោយប្រសិទ្ធភាព និងក្រមសីលធម៌ ការប្រើប្រាស់ MS Excel ដើម្បីផលិតគំនូសតាង ឬអ៊ីស្តូក្រាមពីសំណុំ ទិន្នន័យ សមត្ថភាពក្នុងការប្រើ ប្រាស់បច្ចេកវិទ្យាឌីជីថល ឧបករណ៍ ទំនាក់ទំនង និង/ឬបណ្តាញ ដើម្បីចូលប្រើ គ្រប់គ្រង រួមបញ្ចូល វាយតម្លៃ និងបង្កើតព័ត៌មាន ជំនាញបច្ចេកវិទ្យា ព័ត៌មាន និងទំនាក់ទំនង (ICT) ការថត និងកែសម្រួល សមត្ថភាពក្នុងការឌិកូដ វាយតម្លៃ វិភាគ និងផលិតប្រព័ន្ធផ្សព្វផ្សាយ បោះពុម្ព និងអេឡិចត្រូនិក អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ (ML) ឯកសារតន្ត្រី ទទួលបាន និងចែករំលែកព័ត៌មានក្នុងទម្រង់ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ (ឧ. វីដេអូ តន្ត្រី ផត-ខាស)។ និយមន័យនៃសមាសជាតុទាំងនេះនៃចំណេះដឹងឌីជីថល រួមជាមួយនឹងឧទាហរណ៍ ត្រូវបានដាក់បញ្ចូលគ្នាក្នុងតារាង 2.3។

សំណុំជំនាញទី3៖ ជំនាញជីវិត និងអាជីព ជំនាញជីវិត និងអាជីពជួយសិស្សឱ្យស៊ូទ្រាំនឹងជីវិតស្មុគស្មាញ និង បរិយាកាសការងារនៅក្នុងសេដ្ឋកិច្ចផ្អែកលើចំណេះដឹង និងសកលភាវូបនីយកម្ម។ បន្ថែមពីលើចំណេះដឹង ខ្លឹមសារ និងជំនាញការគិត អ្នកសិក្សាក៏ត្រូវបានរំពឹងថានឹងអភិវឌ្ឍជំនាញទន់

គ្រប់គ្រាន់ដែលបំពាក់ឱ្យពួកគេជាមួយនឹងការត្រៀមខ្លួន ដើម្បីសម្របខ្លួនទៅនឹងបរិយាកាសការងារដែលមានបញ្ហាប្រឈម គ្រប់គ្រងបន្ទុកការងារធ្ងន់ បំពេញតាមពេលវេលាកំណត់ដ៏តឹងរ៉ឹង ក៏ដូចជាធ្វើអន្តរកម្ម និងធ្វើការជាមួយ ដៃគូ របស់ពួកគេនៅក្នុង សម្រេចបាននូវគោលដៅដែលបានព្រមព្រៀងគ្នា។

រូបមន្តនៃការរៀន សតវត្សរ៍ទី២០ដំបូង ដើម្បីធ្វើឱ្យសមាសធាតុស្នូលនៃក្របខ័ណ្ឌ P21 ងាយស្រួលក្នុងការទាញយកមកវិញ Trilling and Fadel (2009) បានរៀបចំឡើងវិញ និងបង្រួមវាទៅជាជំនាញចំនួនប្រាំពីរ ដោយចាប់ផ្តើម ដោយអក្សរ "C" ដែលតំណាងឱ្យការគិតប្រកបដោយការរិះគន់ និងការដោះស្រាយបញ្ហា ការច្នៃប្រឌិត និងការច្នៃប្រឌិត ការសហការ។ ការងារជាក្រុម និងភាពជាអ្នកដឹកនាំ ការយល់ដឹង ឆ្លងវប្បធម៌។ ភាពស្ទាត់ជំនាញផ្នែកទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយ កុំព្យូទ័រ និង ICT ស្ទាត់ជំនាញ អាជីព និងការសិក្សា ការពឹងផ្អែកលើខ្លួនឯង និងជំនាញ "R" ចំនួនបីដែលសំដៅលើការអាន ការសរសេរ និងនព្វន្ត។ ដូច្នេះពួកគេបានសង្ខេបការរៀនសតវត្សរ៍២៤ 3Rsx 7Cs ការរៀនសតវត្សរ៍ទី២០ដំបូង ការត្រិះរិះពិចារណា និងការដោះស្រាយបញ្ហា ការអាន ការសហការភាពច្នៃប្រឌិត និងការច្នៃប្រឌិត ការងារជាក្រុម និងភាពជាអ្នកដឹកនាំ ការសរសេរ អក្សរសាស្ត្រ ការយល់ដឹងពីវប្បធម៌ ភាពស្ទាត់ជំនាញផ្នែកទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយ ភាពស្ទាត់ ជំនាញនៃកុំព្យូទ័រ និង ICT អាជីព និងការសិក្សា ការពឹងផ្អែកលើខ្លួនឯង ឥឡូវនេះ យើងមានមូលដ្ឋានរួមមួយអំពីអ្វីដែលជំនាញសតវត្សរ៍ទី២១ រួមបញ្ចូល។ យើងនឹង ពិនិត្យមើលផែនទីបង្ហាញផ្លូវនៃការអប់រំនៃ ផ្នែកផ្សេងៗនៃពិភពលោកនៅក្នុងជំពូកបន្ទាប់ ដោយព្យាយាមតម្រឹមគោលនយោបាយ និងកំណែទម្រង់ អប់រំជាមួយនឹងការទាមទារដែលបានលើកឡើងនៃសតវត្សទីម្ភៃមួយ។ ប្រព័ន្ធអប់រំជុំវិញពិភពលោកបាន និងកំពុងដំណើរការ កំណែទម្រង់យ៉ាងសំខាន់ ដើម្បីធានាឱ្យក្មេងជំនាន់ក្រោយទទួលបានការ បណ្តុះបណ្តាលដែលអាចឱ្យពួកគេប្រឈមមុខនឹងបញ្ហាប្រឈមដែលនាំមកដោយភាពជឿនលឿននៃ បច្ចេកវិទ្យា និងការផ្លាស់ប្តូរនៅក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ចពិភពលោក ដូច្នេះហើយ វាដើរតួយ៉ាងសំខាន់ ក្នុងការទ្រទ្រង់ការអភិវឌ្ឍន៍របស់ពួកគេ។ នៅក្នុងផ្នែកខាងក្រោម ផែនទីបង្ហាញផ្លូវនៃការ អប់រំនៅហុងកុង ស្វីស សហរដ្ឋអាមេរិក និងតំបន់មួយចំនួនទៀតត្រូវបានបង្ហាញដើម្បីបង្ហាញពីការ អនុវត្តល្អបំផុតដែលគាំទ្រដោយការស្រាវជ្រាវ ពីប្រព័ន្ធអប់រំផ្សេងៗគ្នា និងដើម្បីរំលេចមេរៀនដែល យើងអាចរៀនពីគោលនយោបាយ អប់រំបច្ចុប្បន្នទូទាំងពិភពលោក។

ជំនាញសតវត្សរ៍ទី២០ដំបូង និងផែនទីបង្ហាញផ្លូវនៃការអប់រំនៅហុងកុង ស្វីស និងសហរដ្ឋអាមេរិក។ តារាង 2.4 ចាប់យកគោលដៅនៃ ក្របខ័ណ្ឌអប់រំដែលបានលើកឡើងនៅក្នុងទីក្រុងហុងកុង ស្វីស និងសហរដ្ឋអាមេរិក ដោយប្រើក្របខ័ណ្ឌ P21 ជាចំណុចយោងក្នុងការគូសបញ្ជាក់ ពីភាពខុសគ្នា និងភាពស្រដៀងគ្នារបស់ពួកគេ។ កន្លែងទាំងបី នេះបានអនុវត្តវិធី សាស្ត្រផ្សេងគ្នាចំពោះការអប់រំជំនាញសតវត្សរ៍ទី២១។ នៅក្នុងផ្នែកវងបន្ទាប់ យើង នឹងពិភាក្សាអំពីប្រព័ន្ធអប់រំនៃប្រទេស/តំបន់នីមួយៗឱ្យកាន់តែលម្អិត។

ហុងកុង ក្នុងចំណោម ប្រព័ន្ធអប់រំដ៏ល្បីល្បាញទាំងអស់នៅអាស៊ី យើងបានជ្រើសរើសពង្រីកទៅហុងកុង សម្រាប់ការសិក្សាស្រាវជ្រាវយ៉ាងជិតស្និទ្ធមួយផ្អែកដោយសារតែបរិយាកាសពហុវប្បធម៌ និងលទ្ធភាពទទួលបានបច្ចេកវិទ្យាទំនើបបំផុត ហើយដោយសារអ្នកនិពន្ធសៀវភៅនេះបានធ្វើការទូលំទូលាយ។ ការស្រាវជ្រាវក្នុងតំបន់ ទាក់ទងនឹងគោលគំនិតសំខាន់ៗដែលបានស្វែងរកក្នុងជំពូក។ ដោយសារប្រវត្តិសាស្ត្រអាណានិគមដ៏យូរ មួយសតវត្សរ៍របស់ខ្លួន ហុងកុងគឺជាទីក្រុងអន្តរជាតិមួយក្នុងចំណោមទីក្រុងអន្តរជាតិនៅអាស៊ី ដែលរួមបញ្ចូលគ្នានូវវប្បធម៌ លោកខាងលិច និងបូព៌ាប្រកបដោយភាពសុខដុមរមនាបំផុត។ ក្នុងនាមជា "ទីក្រុងពិភពលោករបស់អាស៊ី" ប្រព័ន្ធអប់រំរបស់ហុងកុងទាក់ទាញក្នុងស្រុក។ និស្សិតចិនដីគោក និងបរទេសជាមួយជំនាញសតវត្សរ៍ទី២១ និងផែនទីបង្ហាញផ្លូវអប់រំ... ២៥ តារាង 2.4 ជំនាញ សតវត្សរ៍ទី២១ និងផែនទីបង្ហាញផ្លូវនៃការអប់រំសកល សតវត្សរ៍ទី២១ EDB (2011b) បានផ្តល់អនុសាសន៍ដល់ហុងកុង រដ្ឋាភិបាលសម្រាប់កំណែទម្រង់ដែលត្រូវធ្វើក្នុងកម្មវិធីសិក្សា យន្តការ វាយតម្លៃ និងប្រព័ន្ធចូលរៀននៅដំណាក់កាលផ្សេងៗនៃការអប់រំ។ កំណែទម្រង់ដែលបានស្នើឡើង ទាំងនេះកើតចេញពីតម្រូវការជាក់ស្តែងនៅក្នុងពិភពផ្លាស់ប្តូរនៃសតវត្សរ៍ទី២១ ដោយមាន គោលបំណង ផ្តល់អំណាចដល់យុវជនហុងកុងជំនាន់ក្រោយជាមួយនឹង "ចំណេះដឹងដែលមានមូលដ្ឋាន ទូលំទូលាយ ការសម្របខ្លួនខ្ពស់ ការគិតដោយឯករាជ្យ និងសមត្ថភាពសម្រាប់ការរៀនសូត្រ ពេញមួយជីវិត" (EDB ឆ្នាំ 2006 ទំព័រ 3) ។ ការរៀនផ្អែកលើការសាកសួរគឺជាលើកដំបូងដែលត្រូវបានណែនាំជាផ្លូវការនៅក្នុងគោលនយោបាយអប់រំរបស់ទីក្រុងក្នុងឆ្នាំ 2008 (EDB 2008)។ វិស័យអប់រំចំនួនបួនត្រូវបានគណៈកម្មការអប់រំកំណត់ថាជាជំនាញសំខាន់ដែល សិស្សានុសិស្សគួរតែអាចអភិវឌ្ឍ និងពង្រឹងក្នុងអំឡុងពេលសិក្សារបស់ពួកគេ រួមមាន ការអប់រំ សីលធម៌ និងពលរដ្ឋ ការអានដើម្បីរៀន ការរៀនគម្រោង និងបច្ចេកវិទ្យាព័ត៌មានសម្រាប់ការសិក្សាអន្តរកម្ម។ គោលដៅសំខាន់ៗចំនួនប្រាំពីរ ដែលបំពេញបន្ថែមលើទិដ្ឋភាពទាំងបួន នេះ ត្រូវបានគេទទួលស្គាល់ថាជា 'គោលបំណងរួមនៃកម្មវិធីសិក្សា' (EDB 2008) ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍន៍រួមរបស់សិស្សក្នុងការអប់រំបឋមសិក្សា និងមធ្យមសិក្សា។ គោលដៅត្រូវបានកំណត់ដោយផ្អែកលើវិធីសាស្ត្រដ៏ទូលំទូលាយមួយដែលផ្តោតលើ ការអភិវឌ្ឍន៍មនុស្សទាំងមូល និងរួមបញ្ចូលមិនត្រឹមតែជំនាញសិក្សាប៉ុណ្ណោះទេ ប៉ុន្តែ ចំណាប់អារម្មណ៍ផ្ទាល់ខ្លួន និងការបង្កើនតម្លៃផងដែរ។ គោលដៅរបស់ EDB អាចលេចឡើង នៅលើផ្ទៃដែលខុសពីជំនាញសតវត្សទីម្ភៃមួយ។ ទោះជាយ៉ាងណាក៏ដោយ ការរំពឹងទុកនៃគោលដៅសិក្សានីមួយៗគឺមានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងជាមួយនឹងសមត្ថភាព ដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងសំណុំជំនាញសតវត្សទីម្ភៃមួយ។

ស្វីស នៅប្រទេសស្វីស អធិបតេយ្យភាពផ្នែកអប់រំ ស្ថិតនៅជាមួយតំបន់ (រដ្ឋជាសមាជិក)។ មិនមែន ជាមួយរដ្ឋាភិបាលសហព័ន្ធទេ ដូច្នេះទិដ្ឋភាពអប់រំនៅប្រទេសស្វីសត្រូវ បានកំណត់លក្ខណៈដោយ អធិបតេយ្យភាពនៃ 26 Cantons និង 4 ភាសាជាតិ។ Canton នីមួយៗមានកម្មវិធីសិក្សាផ្ទាល់ខ្លួន។ ត្រឡប់ទៅឆ្នាំ 2003 គម្រោងមួយដែល មានឈ្មោះថា harmoS (Harmonisierung der obligatorischen Schule: "សុខដុមនីយកម្មនៃសាលាកំហិត") ត្រូវបានចាប់ផ្តើមដោយសន្និសីទនៃ

នាយកសាលា Cantonal of Education (EDK) ។ គោលដៅនៃគម្រោងគឺបង្កើតស្តង់ដារអប់រំ និងកម្មវិធីសិក្សាជាតិមួយសម្រាប់ K12 នៅប្រទេសស្វីស។ កម្មវិធីសិក្សា ជាតិត្រូវបានគេហៅថា "Lehrplan 21" ។ នៅពេលនេះ 15 Canton' មានធន្ទៈក្នុង ការចុះសម្រុងគ្នានឹងកម្មវិធីសិក្សារបស់ពួកគេ។ "Lehrplan 21" រួមបញ្ចូលនូវ គោលបំណងអប់រំជាតិ (ស្តង់ដារអប់រំ) ដូច្នេះជានាបាននូវភាពស្របគ្នាក្នុងចំណោម ប្រព័ន្ធអប់រំ Cantonal និងឆ្លើយតបទៅនឹងការចល័តរបស់គ្រួសារក្នុងប្រទេស ដែលកំពុងតែក្លាយជាការពិត (Amsler 2013)។ អត្ថប្រយោជន៍លេចធ្លោមួយនៃកម្មវិធីសិក្សាថ្មីគឺជំនាញ (សមត្ថភាព) ទិសដៅ- ការងារ។ "Lehrplan 21" ពិពណ៌នាអំពីសមត្ថភាពដែលត្រូវទទួលបានដោយចុងបញ្ចប់នៃ ការអប់រំជាកំហិតនៅអាយុ 16 ឆ្នាំ។ រចនាសម្ព័ន្ធត្រូវបានបង្កើតជាបី Acanton គឺជារដ្ឋសមាជិកនៃរដ្ឋសហព័ន្ធនៃប្រទេសស្វីស។ មាន 26 Cantons នៃ

2.5 ជំនាញម្តៃមួយសតវត្សរ៍ និងផែនទីបង្ហាញផ្លូវអប់រំ... រដ្ឋ ហើយសម្រាប់រដ្ឋនីមួយៗស្តង់ដារអប្បបរមាត្រូវបានកំណត់។ ការរៀបចំយ៉ាងម៉ឺងម៉ាត់នៃ សមត្ថភាពបង្ហាញយ៉ាងច្បាស់ថា តម្រូវការកម្មវិធីសិក្សាមិនទំនងជាត្រូវបានបំពេញដោយគ្រាន់តែ "គ្របដណ្តប់" កម្មវិធីសិក្សានៅក្នុងមុខវិជ្ជាជាក់លាក់ណាមួយនោះទេ។ សិស្សគួរមានជំនាញ ក្នុងមុខវិជ្ជា។ ការមានសមត្ថកិច្ចមានន័យថាមានចំណេះដឹងចាំបាច់ និងអាចអនុវត្ត ចំណេះដឹងនេះក្នុងស្ថានភាពជាក់លាក់មួយ (Amsler 2013)។ "ICT and Media" មានកន្លែង ផ្ទាល់ខ្លួននៅក្នុងកម្មវិធីសិក្សា ហើយត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានីមួយៗ។ នៅក្នុង "Lehrplan 21" គោលបំណងនៃ "ICT and Media" គឺត្រូវប្រាកដថាអ្នកសិក្សាអាចចូលរួមក្នុងសង្គមប្រព័ន្ធផ្សព្វផ្សាយថ្ងៃនេះ និងថ្ងៃស្អែកក្នុងនាមជាបុគ្គលដែល សម្រេចចិត្តដោយខ្លួនឯង មានគំនិតច្នៃប្រឌិត និងមានភាពចាស់ទុំ ព្រមទាំងមានអាកប្ប កិរិយាសមរម្យ និងសង្គម។ របៀបទទួលខុសត្រូវ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងតំបន់នេះ បញ្ហា ផ្សេងៗលើសពីកម្មវិធីសិក្សាជាក់ស្តែងនៅតែត្រូវដោះស្រាយ ដូចជា លក្ខខណ្ឌក្របខ័ណ្ឌ យុត្តាធិការ និង (មូលដ្ឋាន និងបន្ថែម) ការបណ្តុះបណ្តាលគ្រូ (Amsler 2013)។ គំនិតផ្តួចផ្តើមមួយផ្សេងទៀតដែលដឹកនាំដោយបណ្ឌិត្យសភាវិទ្យាសាស្ត្រវិស្វកម្ម ស្វីសកំណត់គោលដៅបច្ចេកវិទ្យាថ្មី និងការស្វែងរកនិន្នាការអប់រំ (SATW) (Jobin and Morel 2012)។ SATW ត្រូវបានទទួលស្គាល់ថាជាអង្គការចម្បងសម្រាប់ការប្រាស្រ័យ ទាក់ទងនៃព័ត៌មានឯករាជ្យ គោលបំណង និងទូលំទូលាយអំពីបច្ចេកវិទ្យា - ជាមូលដ្ឋាន សម្រាប់ការបង្កើតគំនិតដែលបានបង្កើតឡើងយ៉ាងល្អ និងជាស្ថាប័នដ៏មានប្រសិទ្ធភាពសម្រាប់ ការលើកកម្ពស់វិទ្យាសាស្ត្រវិស្វកម្ម និងបច្ចេកវិទ្យាថ្មីនៅក្នុងប្រទេសស្វីស។ដោយផ្អែកលើសមត្ថភាពសំខាន់ៗសម្រាប់ការរៀនសូត្រពេញមួយជីវិត ដែលស្នើឡើង ដោយអនុសាសន៍ 2006/992/EC នៃសភាអឺរ៉ុប (Europa 2006) SATW បានស្នើរម៉ាទ្រីសនៃសមត្ថភាពឆ្លងដែន ដូចជាការសហការ ការប្រាស្រ័យទាក់ទង យុទ្ធសាស្ត្រសិក្សា ការគិតប្រកបដោយភាពច្នៃប្រឌិត និងការឆ្លុះបញ្ចាំងដោយខ្លួនឯង វិធីសាស្ត្រដែលត្រូវអនុវត្តក្នុង ការអប់រំទូទៅដែលមានប្រព័ន្ធផ្សព្វផ្សាយ និង ICT សុខភាព ការសិក្សាក្នុងគម្រោង លទ្ធិប្រជាធិបតេយ្យ សង្គម

និងបរិស្ថាន និងការអប់រំផ្អែកលើមុខវិជ្ជាជាក់លាក់មួយនៅក្នុង មុខវិជ្ជាសាលាដូចខាងក្រោម៖ ភាសា គណិតវិទ្យា និងវិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម សិល្បៈ។ និងកីឡា។ 2.5.3 សហរដ្ឋអាមេរិក ការិយាល័យស្ថិតិការងាររបស់សហរដ្ឋអាមេរិកបានព្យាករណ៍ថាចំនួនការងារក្នុងជំនាញកុំព្យូទ័រ និងវិទ្យាសាស្ត្រព័ត៌មានត្រូវបានគេរំពឹងថានឹងកើនឡើងច្រើនជាងពីរដងនៃអត្រានៃមុខតំណែងទាំងអស់នៅក្នុង ផ្នែកវិស្វកម្ម វិទ្យាសាស្ត្រជីវិត វិទ្យាសាស្ត្រធម្មជាតិ និងវិទ្យាសាស្ត្រ រូបវិទ្យានៅឆ្នាំ 2018 ( Lacey និង Wright 2009)។ កាន់តែទូលំទូលាយ បច្ចេកវិទ្យា បានក្លាយជារឿងធម្មតានៅក្នុងកន្លែងធ្វើការនៅសហរដ្ឋអាមេរិក និងវិស័យវិជ្ជាជីវៈ។ ទិន្នន័យ ស្ទង់មតិពី Pew Research នៅចុងឆ្នាំ 2013 បង្ហាញថា ក្នុងចំណោមគំរូចៃដន្យនៃនិយោជិក នៅសហរដ្ឋអាមេរិក 94% ប្រើប្រាស់អ៊ីនធឺណិតនៅកន្លែងធ្វើការ តំណាងឱ្យសហគ្រាសគ្រប់ប្រភេទ ពីក្រុមហ៊ុនបច្ចេកវិទ្យារហូតដល់ក្រុមហ៊ុនមិនមែនបច្ចេកវិទ្យា ពីសាជីវកម្មធំរហូតដល់ ប្រតិបត្តិការម្ចាស់តូច និងពី អ្នកដែលនៅតំបន់ទីក្រុង កសិដ្ឋាន និងកន្លែងនៅចន្លោះ (Purcell and Rainie 2014)។ ជាងនេះទៅទៀត ការងារជាច្រើនទាមទារឱ្យមានការប្រើប្រាស់ឯកទេស នៃកម្មវិធីកុំព្យូទ័រ ឧបករណ៍ផលិតភាព និងសេវាកម្មគេហទំព័រ ហើយកុំព្យូទ័រកាន់តែច្រើនឡើង ត្រូវបានដាក់ពង្រាយដើម្បីគ្រប់គ្រង និងដំណើរការឧបករណ៍បច្ចេកទេស ឧបករណ៍ និងគ្រឿងម៉ាស៊ីន។ មន្ត្រីរដ្ឋាភិបាល អ្នកបង្កើតគោលនយោបាយ អ្នកដឹកនាំអប់រំ និងអ្នកប្រាជ្ញដូចគ្នា យល់ស្របថា នៅពាក់កណ្តាលនៃការផ្លាស់ប្តូរពិភពលោកនេះ ទៅជាការជំរុញចំណេះដឹង។

បោះពុម្ព ចែករំលែក 2 ជំនាញសតវត្សរ៍ទី២០ដំបូង និងផែនទីបង្ហាញផ្លូវនៃការអប់រំសកល សេដ្ឋកិច្ចតម្រូវឱ្យយុវជនត្រៀមខ្លួនឱ្យបានគ្រប់គ្រាន់ក្នុងអំឡុងពេលសិក្សាសាធារណៈ សម្រាប់ការប្រើប្រាស់បច្ចេកវិទ្យា។ អ្នកនិពន្ធសៀវភៅនេះ សុទ្ធតែមានទស្សនៈដូចគ្នា។ ការអប់រំ ត្រូវតែពង្រីកការរៀនសូត្ររបស់សិស្សនៅក្នុងសាលាលើសពីការអាន ដើម្បីរួមបញ្ចូលការសាកសួរ ការរកឃើញ ការគិតបែបរិះគន់ ផលិតភាព និងការបង្កើតប្រកបដោយភាពច្នៃប្រឌិតជាមួយនឹងបច្ចេកវិទ្យា ដើម្បីគាំទ្រដល់ដំណើរព័ត៌មានទៅចំណេះដឹងរបស់សិស្ស និងការរីកចម្រើនផ្ទាល់ខ្លួន សង្គម និងវប្បធម៌របស់ពួកគេ ព្រមទាំងជីវភាពរស់នៅផងដែរ។ (AASL 2007 International Society for Technology in Education [ISTEJ 2007; National Education Technology Plan [NETP] 2010) ដូចប្រទេសជាច្រើនផ្សេងទៀត ប្រព័ន្ធអប់រំរបស់សហរដ្ឋអាមេរិកគឺនៅក្នុងវិធីជាច្រើនដែលត្រូវ បានជំរុញដោយតម្រូវការសាកល្បង។ នៅក្រោមច្បាប់ "No Child Left Behind" (NCLB) នៅ សហរដ្ឋអាមេរិក ការអប់រំសាធារណៈគឺអាចរកបានជាសកល ជាមួយនឹងការគ្រប់គ្រង និងការផ្តល់មូលនិធិមកពីរដ្ឋ មូលដ្ឋាន និងរដ្ឋាភិបាលសហព័ន្ធ។ កម្មវិធីសិក្សារបស់សាលារដ្ឋ ការផ្តល់មូលនិធិ ការបង្រៀន ការងារ និងគោលនយោបាយផ្សេងទៀត ត្រូវបានកំណត់តាមរយៈក្រុមប្រឹក្សាសាលាដែលជាប់ឆ្នោតក្នុងតំបន់ ដែលមានយុត្តាធិការលើមណ្ឌលសិក្សានីមួយៗ។ រដ្ឋាភិបាលរដ្ឋកំណត់ស្តង់ដារអប់រំ និងកំណត់ការប្រឡងស្តង់ដារសម្រាប់ប្រព័ន្ធសាលារៀនសាធារណៈ។ NCLB ផ្តោតលើការវាយតម្លៃផ្អែកលើការសាកល្បង និងសមត្ថភាពគណនីរបស់សាលា/គ្រូនៅក្នុងកម្មវិធីសិក្សាស្នូលរបស់សហរដ្ឋអាមេរិកបែបបុរាណនៃ

គណិតវិទ្យា វិទ្យាសាស្ត្រ សិល្បៈភាសាអង់គ្លេស/ភាសា និងការសិក្សាសង្គម។ ភាពចាំបាច់នៃការធ្វើតេស្តទាំងនេះបញ្ឆាក់ពីកិច្ចខិតខំប្រឹងប្រែងកែលម្អសាលារៀន និងកាន់តែខ្លាំងឡើង កម្មវិធីសិក្សា និងគរុកោសល្យថ្នាក់រៀនប្រចាំថ្ងៃ។ នៅចុងរដូវស្លឹកឈើជ្រុះឆ្នាំ 2015 NCLB ត្រូវ បានជំនួសដោយច្បាប់ស្តីពីភាពជោគជ័យរបស់សិស្សគ្រប់រូប (ESSA) ដែលជាច្បាប់ថ្មីមួយដែល ប្រធានាធិបតីសហរដ្ឋអាមេរិកលោក Barack Obama ត្រូវបានគេរំពឹងថានឹងចុះហត្ថលេខាលើច្បាប់។ ច្បាប់ នេះផ្លាស់ប្តូរការតស៊ូដើម្បីការរស់រានមានជីវិតនៃការអប់រំសាធារណៈ និងវិជ្ជាជីវៈគ្រូបង្រៀន ទៅកាន់រដ្ឋសហរដ្ឋអាមេរិក។ ឥឡូវនេះរដ្ឋនឹងមានការសម្រេចចិត្តយ៉ាងទូលំទូលាយនៅក្នុងគោលដៅ និងគោលបំណង គណនេយ្យភាព ការវាស់វែងការអនុវត្ត និងការគ្រប់គ្រងអន្តរាគមន៍នៅក្នុងសាលារៀនដែល មានដំណើរការទាប។ ការធ្វើតេស្តនឹងដើរតួនាទីសំខាន់ ប៉ុន្តែរដ្ឋនានានឹងត្រូវបានចោទប្រកាន់ក្នុង ការកំណត់អត្តសញ្ញាណកត្តាផ្សេងទៀតដែលមានអាទិភាពសម្រាប់ការរៀនសូត្រ ស្របតាមប្រជាជនដែល បានធ្វើមូលដ្ឋានីយកម្ម។ គំនិតផ្តួចផ្តើមស្តង់ដាររដ្ឋស្នូលរួមបានជំរុញឱ្យមានការពិភាក្សាថ្នាក់ជាតិជុំវិញ កំណែទម្រង់កម្មវិធីសិក្សា ហើយរដ្ឋចំនួន 47 និងស្រុកកូឡុំប៊ីបានចុះហត្ថលេខាលើ។ ស្តង់ដារកម្រិតជាតិថ្មីទាំងនេះ រួមមានយុទ្ធសម្រាប់ជំនាញឌីជីថល និងព័ត៌មាន។ ដើម្បីបន្តទៅមុខទៀត ផែនការបច្ចេកវិទ្យាអប់រំជាតិនៃឆ្នាំ 2010 ផ្តល់នូវការហៅស៊ីរ៉ែន សម្រាប់ភាពជឿនលឿននៅក្នុងបទពិសោធន៍សិក្សាផ្ទាល់ខ្លួនដែលផ្តោតលើសិស្ស ផ្តោត លើការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការបង្រៀន ការរៀន និងការគ្រប់គ្រង។ ផែនការនេះក៏អំពាវនាវឱ្យមានការស្រាវជ្រាវ ការអភិវឌ្ឍន៍ និងការធ្វើពាណិជ្ជកម្មកាន់តែច្រើនឡើងនៃ ការច្នៃប្រឌិតប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កើនបទពិសោធន៍សិក្សាសម្រាប់យុវជន (នៅក្នុង ប្រធានបទប្រពៃណី និងក្នុងដែនដែលបច្ចុប្បន្នមិនត្រូវបានផ្តល់អាទិភាពដោយ Canon ប្រពៃណី ដូចជាវិទ្យាសាស្ត្រកុំព្យូទ័រ/ការគិតគណនា)។ ផែនការគឺសក្តិសមក្នុងការវិនិយោគ gation ដូចដែលវាផ្តល់នូវផែនទីបង្ហាញផ្លូវសម្រាប់កំណែទម្រង់ដ៏ធំទូលាយ ហើយត្រូវ បានព្រាងដោយអ្នកច្នៃប្រឌិតមួយចំនួនក្នុងការស្រាវជ្រាវអប់រំ រួមទាំងការងារមួយចំនួនដែល មានទីតាំងនៅក្នុងវិន័យស្រាវជ្រាវដែលទើបលេចចេញថ្មីនៃ "វិទ្យាសាស្ត្រសិក្សា"។ មានក្របខ័ណ្ឌស្តង់ដារគួរឱ្យកត់សម្គាល់មួយចំនួន ដែលនិយាយអំពីជំនាញ សតវត្សរ៍ទី២១ នៅក្នុងសហរដ្ឋអាមេរិក។ ក្របខ័ណ្ឌស្តង់ដាររដ្ឋស្នូលទូទៅ (CCSS) ឆ្លុះបញ្ចាំងពី កម្មវិធីសិក្សាស្នូលកម្រិតជាតិនៅសហរដ្ឋអាមេរិកនៅក្នុងប្រធានបទនៃភាសាអង់គ្លេស

2.5 ជំនាញ២១ ផែនទីបង្ហាញផ្លូវនៃការអប់រំ... ២៩ ភាសាសិល្បៈ/អក្ខរកម្ម (ELAL) និងគណិតវិទ្យា។ ស្តង់ដារ CCSS ភ្ជាប់ សារៈសំខាន់យ៉ាងខ្លាំងចំពោះការអនុវត្តជំនាញការគិតលំដាប់ខ្ពស់ដែលរួមបញ្ចូលជាមួយឧបករណ៍ បច្ចេកវិទ្យាជាច្រើនសម្រាប់ការអភិវឌ្ឍចំណេះដឹងយ៉ាងម៉ត់ចត់ និងកម្មវិធីរបស់វាក្នុង ការដោះស្រាយបញ្ហាពិភពលោក (CCSS 2010)។ ស្តង់ដារការអាន ការសរសេរ និងការស្រាវជ្រាវរបស់វាតម្រូវឱ្យសិស្សយល់ វាយតម្លៃ និងបង្ហាញព័ត៌មាន គំនិត និង ភស្តុតាងដែលស្មុគស្មាញកាន់តែខ្លាំងឡើងតាមរយៈការអាន ការស្តាប់ និងការនិយាយ ព្រមទាំងតាមរយៈការចូលរួមជាមួយបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយគ្រប់ ទម្រង់ទាំងអស់ (CCSS 2010)។ សមាគមពីរ

ផ្សេងទៀត សមាគមអន្តរជាតិសម្រាប់បច្ចេកវិទ្យាក្នុងការអប់រំ (ISTE) និងសមាគមបណ្ណារក្សសាលាអាមេរិក (AASL) បានចេញ ស្តង់ដារក្នុងឆ្នាំ 2007 សម្រាប់ចំណេះដឹងផ្នែកឌីជីថល និងព័ត៌មានដែលរួមបញ្ចូល លទ្ធផលជាពិសេសទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យាច្នៃប្រឌិត និងការកំណត់ទីតាំងសម្រាប់ផលិតភាពជាមួយ ឧបករណ៍បច្ចេកវិទ្យា (ISTE 2007; AASL 2007)។ 2.6 តម្រូវការសម្រាប់វិធីសាស្ត្រគរុកោសល្យផ្អែកលើការស៊ើបអង្កេត នៅដើមជំពូក ការប្រៀបធៀបនៃក្របខ័ណ្ឌជំនាញចំនួន២០ដំបូង បានបង្ហាញថាវាប្រែប្រួលក្នុងបរិបទអន្តរជាតិ ប៉ុន្តែជាទូទៅ ភាពសាមញ្ញបច្ចុប្បន្ន ដែលអាចត្រូវបានគេយោងឆ្លងកាត់។ បន្ទាប់មក យើងបានរំលេច គំរូដ៏លេចធ្លោមួយសម្រាប់ជំនាញសតវត្សរ៍ទី២១ ដែលត្រូវបានបង្កើតឡើងនៅក្នុង សហរដ្ឋអាមេរិក (ដូចជា P21 ។ នៅក្នុង 2.4 យើងបានពិភាក្សាអំពី កំណែទម្រង់អប់រំនៅក្នុងទីក្រុងហុងកុង ប្រទេសស្វីស និងកំណែទម្រង់របស់សហរដ្ឋអាមេរិកនៅក្នុងកន្លែងទាំងបី សំដៅទៅលើជំនាញសតវត្សរ៍ទី២១ ទោះបីជាស្ថិតនៅក្រោមគំរូឬក្របខ័ណ្ឌផ្សេងគ្នាក៏ដោយ។ ដូច្នេះវាជាការ សមរម្យក្នុងការនិយាយថាអ្នកបង្កើតគោលនយោបាយជាទូទៅទទួលស្គាល់សារៈសំខាន់នៃជំនាញបែបនេះនៅក្នុងដំណើរការសិក្សារបស់មនុស្សម្នាក់ និងនៅកន្លែងធ្វើការ។ ដែនកំណត់មួយនៃគំរូជំនាញនៃសតវត្សរ៍ទី២១គឺថាខណៈពេលដែលពួកគេបញ្ជាក់ពីគោលបំណង សិក្សាជាអាទិភាព ពួកគេមិនផ្តល់ឱ្យអ្នកអប់រំនូវ "មធ្យោបាយ" ដែលដើម្បីសម្រេចបាន នូវ "ការបញ្ចប់" ដែលបានបញ្ជាក់នោះទេ។ អ្នកដឹកនាំសាលា គ្រូបង្រៀន និងអ្នកធ្វើការ សម្រេចចិត្តត្រូវយល់កាន់តែច្បាស់អំពី "អ្វីដែលដំណើរការ" ។ អង្គការយូណេស្កូកំពុង អនុវត្តគម្រោងក្នុងតំបន់ដើម្បីវាយតម្លៃជំនាញឆ្លងដែន (UNESCO 2015)។ នេះ បង្ហាញពីភាពពាក់ព័ន្ធនៃសាលាជំនួយ។ ការស្រាវជ្រាវអប់រំ និងការបោះពុម្ពផ្សាយ តាមអ្នកប្រាជ្ញក្នុងប្រទេស និងតំបន់នីមួយៗ ដែលបានពិភាក្សាក៏ដូចជាអន្តរជាតិគាំទ្រ កិច្ចខិតខំប្រឹងប្រែងទាំងនេះ ប៉ុន្តែជារឿយៗខ្វះការសម្របសម្រួល និងការផ្សព្វផ្សាយ ការរកឃើញពីតំបន់មួយទៅតំបន់មួយ ឆ្លងកាត់វិញ្ញាសា រារាំងដល់វឌ្ឍនភាព។ សៀវភៅនេះមានគោលបំណងសំយោគអក្សរសិល្ប៍មួយចំនួនលើវិធីសាស្ត្រគរុកោសល្យការស៊ើបអង្កេត លើបច្ចេកវិទ្យា ដោយផ្តោតលើការសិក្សាអនុវត្តជាក់ស្តែង។ សិស្សទទួលបាន ជំនាញសតវត្សរ៍ទី២១ ពេញមួយដំណើរការសាកសួរ ដែលដឹកនាំដោយគ្រូនៅតាមផ្លូវ (Kuhlthau et al. 2007, 2015)។ នៅក្នុង Chaps ។ 3-5 យើងបង្ហាញលទ្ធផលជាក់ស្តែងពី ការសិក្សាអនុវត្តជាច្រើន ហើយបង្ហាញពីការអនុវត្តល្អបំផុតសម្រាប់ការអប់រំជំនាញសតវត្ស

## ៩.៤ សន្និដ្ឋាន

មេរៀននេះផ្តោតលើជំនាញសតវត្សរ៍ទី២១នាពេលបច្ចុប្បន្ន មាន១៣ជំនាញសំខាន់ៗនៃសតវត្សរ៍ទី២១ សម្រាប់សិស្សានុសិស្សនា សម្រាប់ការបង្រៀន និងការរៀននៅសតវត្សរ៍ទី២១។ សិស្សនឹងពិភាក្សាអំពីជំនាញសតវត្សរ៍ទី២១ និងរបៀបដែលគ្រូអាចដើរតួនាទីក្នុងការសម្រេចបាននូវជំនាញទាំងនោះ។

# មេរៀនទី ១០
# កម្មវិធីសាលាកុមារមេត្រី និងសមាសភាគទាំង ៦ នៃសាលាកុមារមេត្រី

## ១០.១ វត្ថុបំណង

បន្ទាប់ពីសិក្សាមេរៀននេះចប់គរុសិស្សអាចៈ

- យល់ច្បាស់ពីសារតារនៃកម្មវិធីសាលាកុមារមេត្រី និងសមាសភាគទាំង៦ នៃសាលាកុមារមេត្រី
- បកស្រាយបានពីសមាសភាគទាំង ៦
- យកចំណេះដឹងទាំងនេះទៅអនុវត្តក្នុងការបង្រៀន និងរៀន ។

## ១០.២ សេចក្ដីផ្ដើម

### សាវតារ

នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ក្រសួងអប់រំ យុវជន និងកីឡារួមសហការជាមួយអង្គការយូនីសេហ្វ(UNICEF) អង្គការន័រវេស៍សង្គ្រោះកុមារកម្ពុជា(SCN) អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា(KAPE) តំណាងខេត្ត-ក្រុងដែលបានសាកល្បង កម្មវិធីសាលាកុមារមេត្រីរៀបចំចងក្រងជាឯកសារមួយស្តីពី "សាលាកុមារមេត្រី" ដែលជាក្របខណ្ឌការងារសម្រាប់អនុវត្តនៅទូទាំងប្រទេសកម្ពុជានាពេលអនាគត ដោយបន្សុីគ្នារវាងបទពិសោធនៃការអនុវត្តក្នុងប្រទេស និងបទពិសោធក្នុងតំបន់សំដៅឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការកែលម្អគុណភាពកម្រិតអប់រំមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ។

ដោយឡែកនៅឆ្នាំ២០០៣នាយកដ្ឋានបណ្តុះបណ្តាលហ្វឹងវិក្រឹត្យការបានសហការជាមួយអង្គការយូនីសែ(UNICEF) និងអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (KAPE) បំប៉នឯកសារកម្មវិធីសាលាកុមារមេត្រីដល់គ្រូឧទ្ទេសនិងគរុសិស្សនៅសាលាគរុកោសល្យ និងវិក្រឹត្យការខេត្តកំពង់ចាម កំពង់ស្ពឺកំពង់ធំ ព្រៃវែង ស្វាយរៀង និងស្ទឹងត្រែង ។ ក្រោយមក នៅឆ្នាំសិក្សា២០០៦-២០០៧ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការបញ្ចូលកម្មវិធីសាលាកុមារមេត្រី ទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូ និងបានសហការជាមួយអង្គការយូនីសេហ្វ (UNICEF) និងអង្គការន័រវេស៍សង្គ្រោះកុមារកម្ពុជា (SCN) រៀបចំកសាងឯកសារកម្មវិធីសាលាកុមារមេត្រីសម្រាប់បណ្តុះបណ្តាលគ្រូ និងបំប៉នសមត្ថភាពជូនដល់គ្រូឧទ្ទេស ដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលគ្រូ ។

## ១០.៣ ខ្លឹមសារ

### ១០.៣.១ និយមន័យសាលាកុមារមេត្រី

សាលាកុមារមេត្រី គឺជាសាលារៀនដែលទទួលស្គាល់ជួយគាំទ្រនូវលទ្ធផលសិក្សារបស់សិស្សដោយផ្អែកលើសិទ្ធិកុមារជាមូលដ្ឋាន ។ សាលាកុមារមេត្រីសហការជាមួយគ្រប់អ្នកពាក់ព័ន្ធ ពិសេសមាតាបិតា ឬអាណាព្យាបាលសិស្ស និងផ្តល់តម្លៃខ្ពស់ដល់ការងារអប់រំ ដោយខិតខំប្រឹងប្រែងចូលរួមចូលរួមចំណែកក្នុងការស្វែងរកកុមារឱ្យចូលរៀនគ្រប់គ្នា និងបង្កើតបរិស្ថានសិក្សាដ៏កក់ក្តៅសំដៅឱ្យកុមារទាំង

នោះបានចូលរៀនប្រកបដោយគុណភាព និងប្រសិទ្ធភាពស្របតាមតម្រូវការជាក់ស្តែងរបស់ពួកគេ។ បរិស្ថានសិក្សាសាលាកុមារមេត្រីបង្ហាញនូវលក្ខណៈសមធម៌ សមភាព សេរីភាព សាមគ្គីភាព គ្មានអំពើហិង្សារួមទាំងសុខភាពរាងកាយ បញ្ញា និងផ្លូវចិត្តដែលកិច្ចធានាក្នុងការអភិវឌ្ឍកុមារឱ្យមានសមត្ថភាពប្រកបដោយចំណេះដឹង បំណិន ឥរិយាបថ តម្លៃ និងសីលធម៌ល្អដើម្បីឱ្យពួកគេចេះរួមរស់នៅជាមួយគ្នាក្នុងភាពសុខដុមរមនា ។

សាលាកុមារមេត្រីជានិច្ចកាលមានភាពស្និទ្ធស្នាល និងស្លាញ់កុមារ ជួយគាំទ្រកុមារឱ្យមានការអភិវឌ្ឍព្រមទាំងមានមេត្រីភាពចំពោះសហគមន៍ ។




## ១០.៣.២ សមាសភាគទាំង៦នៃសាលាកុមារមេត្រី

ដើម្បីអនុវត្តកម្មវិធីសាលាកុមារមេត្រី ត្រូវផ្អែកលើខ្លឹមសារសំខាន់ៗដែលមានសមាសភាគទាំង៦ ដូចខាងក្រោម៖

១- កុមារទាំងអស់បានចូលរៀន
២- ការសិក្សាប្រកបដោយប្រសិទ្ធភាព
៣- សុខភាព សុវត្ថិភាព និងការការពារកុមារ
៤- ការឆ្លើយតបទៅនឹងយេនឌ័រ
៥- ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍
៦- ការគាំទ្រកម្មវិធីពីប្រព័ន្ធអប់រំ ។

### ក) សមាសភាគទី១ ៖ កុមារទាំងអស់បានចូលរៀន

កុមារទាំងអស់បានចូលរៀនសំដៅដល់ការយកចិត្តទុកដាក់របស់អ្នកពាក់ព័ន្ធក្នុងការប្រមូល និងជំរុញកុមារគ្រប់រូបឱ្យទទួលបានការអប់រំប្រកបដោយសមធម៌ ។

❖ **គោលបំណង**

ធានាឱ្យកុមារទាំងអស់ពិសេសកុមារជួបការលំបាក (កុមារក្រីក្រ កុមារី កុមារកំព្រា កុមាររងគ្រោះដោយអំពើហិង្សា កុមារពិការ កុមារជនជាតិភាគតិច កុមាររងគ្រោះដោយមេរោគអេដស៍/ជំងឺអេដស៍) បានចូលរៀនប្រកបដោយសមធម៌ ។

❖ **ខ្លឹមសារ និងសកម្មភាពអនុវត្ត**

▪ **ការគ្រប់គ្រងទិន្នន័យព័ត៌មាន**

- បំប៉នអំពីការគ្រប់គ្រងទិន្នន័យព័ត៌មាន
- រៀបចំគណៈកម្មការអភិវឌ្ឍសាលារៀន
- ប្រមូលចងក្រងស្ថិតិព័ត៌មានពីកុមារតាមរយៈគ្រួសារ
- បូកសរុបជាប្រចាំនូវទិន្នន័យព័ត៌មាន
- កំណត់បញ្ហាដែលបានមកពីការវិភាគទិន្នន័យព័ត៌មាន និងរកធនធានសម្ភារៈជួយដោះស្រាយ
- រៀបចផែនទីខ្នងផ្ទះតាមភូមិនីមួយៗ
- រៀបចំយុទ្ធនាការប្រមូលកុមារឱ្យចូលរៀន
- រៀបចំទទួលចុះឈ្មោះកុមារឱ្យចូលរៀន
- ផ្ទៀងផ្ទាត់ចំនួនសិស្សចូលរៀន បន្ទាប់ពីបវេសនកាល
- ចងក្រងឯកសារស្តីពីសកម្មភាពរបស់សាលា និងសហគមន៍ ដើម្បីជួយកុមារជួបការលំបាក

▪ **ការគាំទ្រ**

- រៀបចំបរិស្ថានសាលារៀនឱ្យមានសោភ័ណភាព ដើម្បីទាក់ទាញកុមារឱ្យចូលរៀន និងរៀនប្រកបដោយគុណភាព ( សួនច្បារ ដើមឈើ ទឹកស្អាត ទីលានកីឡា បង្គន់ស្អាត បន្ទប់រៀនស្អាត សួនបណ្តុះរុក្ខជាតិ តូបអាន រុក្ខជាតិទឹក ... )។
- កសាងជម្រាលនៅមុខថ្នាក់រៀន ដើម្បីជួយសម្រួលដល់សិស្សពិការ
- រៀបចំកន្លែងរៀនឱ្យបានសមរម្យ ( អគារ រោងដោល សំយ៉ាប ... )
- រៀបចំបង្គន់អនាម័យឱ្យបានសមរម្យតាមចំនួនសិស្ស ពិសេសមានបង្គន់សម្រាប់សិស្សពិការ និងសិស្សស្រី
- រៀបចំសួនកុមារសម្រាប់សិស្សពិការ
- បង្កើតសាលារៀនកម្រិតអប់រំមូលដ្ឋាននៅតាមឃុំ
- រៀបចំថ្នាក់ ឬសាលាឆ្លងកាត់ ដើម្បីសម្រួលដល់កុមារដែលមានផ្ទះនៅឆ្ងាយពីសាលារៀន
- រៀបចំថ្នាក់សង្គ្រោះបន្ទាន់
  ដើម្បីជួយកុមារដែលមានអាយុច្រើនរៀននៅបឋមសិក្សាក្នុងរយៈពេល៣ឆ្នាំ បាន៦កម្រិតថ្នាក់
- រៀបចំថ្នាក់បំប៉នបង្រៀនសិស្សរៀនយឺតស្របពេលនៅតាមមូលដ្ឋានរបស់សហគមន៍
- រៀបចំការជួយសិស្សរៀនយឺតនៅតាមផ្ទះ ពិសេសថ្នាក់ទី១ និងទី២
- រៀបចំថ្នាក់បញ្ញើ ដើម្បីជួយសិស្សដែលទៅតាមឪពុកម្តាយចល័តមុខរបរ

- រៀបចំកម្មវិធីគ្រូបង្រៀនចល័ត
- កម្មវិធីថ្នាក់គួប
- ពង្រីកសាលារៀនឱ្យបានគ្រប់កម្រិតថ្នាក់
- បង្កើតឱ្យមានថ្នាក់មត្តេយ្យនៅក្នុងបឋមសិក្សា
- រៀបចំកាលវិភាគ ប្រតិទិនសិក្សា ទីកន្លែងសមស្របសម្រាប់កុមារជួបការលំបាកក្នុងការសិក្សា
- រៀបចំសកម្មភាពក្រុមកុមារជួយកុមារ ដើម្បីផ្តល់ព័ត៌មានជូន និងនាំគ្នាមករៀន ជួយបង្រៀននៅក្នុងថ្នាក់រៀន ក្រៅថ្នាក់រៀនឱ្យបានរៀនសូត្រប្រកបដោយសមធម៌ ។
- បង្កើតហិបប្រមូលបច្ច័យនៅតាមវត្តអារាម ភូមិ ផ្សារ ហាង ដើម្បីជួយសង្គ្រោះដល់កុមារជួបការលំបាកឱ្យទទួលបានការអប់រំដូចកុមារដទៃទៀត
- រៀបចំឥណទានសាលារៀន ដើម្បីជួយដល់កុមារជួបការលំបាក
- រៀបចំក្រុមកុមារសន្សំប្រាក់ ដើម្បីយកកម្រៃការប្រាក់សម្រាប់ឧបត្ថម្ភ ដល់កុមារជួបការលំបាក
- រៀបចំកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន
- ធ្វើទំនាក់ទំនងជាមួយអង្គការ សប្បុរស ជននានាក្នុង និង ក្រៅប្រទេសឱ្យជួយ (ផ្តល់អាហារូបករណ៍ ផ្តល់អាហារូបត្ថម្ភ រៀបចំថ្នាក់អប់រំពិសេស / ថ្នាក់សមាហរណកម្ម និងបញ្ជូនកុមារពិការទៅព្យាបាល ) ។

### ខ)សមាសភាគទី២ ៖ ការសិក្សាប្រកបដោយប្រសិទ្ធភាព

ការសិក្សាប្រកបដោយប្រសិទ្ធភាព ជាសកម្មភាពរៀននិងបង្រៀនក្នុងបរិយាកាសសប្បាយរីករាយប្រកបដោយគុណភាព និងសមធម៌ ។

❖ **គោលបំណង**

ដើម្បីអភិវឌ្ឍសមត្ថភាពរបស់គ្រូឱ្យជានាបាននូវចំណេះដឹង បំណិន សីលធម៌ និងចេះរួមរស់ ជាមួយគ្នារបស់សិស្សទាំងអស់ ។

❖ **ខ្លឹមសារ និងសកម្មភាពអនុវត្ត**

▪ **ការពង្រឹងលើការងារគ្រប់គ្រងបច្ចេកទេស**

- ពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងបច្ចេកទេស ប្រធានក្រុមបច្ចេកទេសតាមកម្រិតថ្នាក់ តាមសាលារៀន និងកម្រង
- ធ្វើបំណែងចែកកម្មវិធីសិក្សា និងការងារចាត់តាំងឱ្យបានសមស្រប
- ប្រមូល និងវិភាគទិន្នន័យព័ត៌មានជុំវិញការបង្រៀន និងរៀន
- កសាងផែនការបំប៉នបច្ចេកទេស
- រៀបចំផែនការចុះជួយពង្រឹងការបង្រៀន និងរៀន
- ពង្រឹងគណៈកម្មការ និងក្រុមប្រឹក្សានានា
- បូកសរុបវាយតម្លៃលើការងារបង្រៀន និងរៀន ។

▪ **ការបង្រៀន និងរៀន**

- សម្របសម្រួលខ្លឹមសារមេរៀនទាំង៤មុខវិជ្ជាគោលឱ្យសមស្របនឹងការយល់ដឹងរបស់សិស្ស
- បំប៉នគ្រូពីកម្មវិធីថ្នាក់គួប ថ្នាក់សង្គ្រោះបន្ទាន់ ថ្នាក់អប់រំបញ្ចូលគ្នា
- ពង្រឹងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល
- ចុះសិក្សាស្វែងយល់ដល់ទីកន្លែង ( ការចិញ្ចឹមសត្វ ដាំបន្លែ )
- សកម្មភាពស្រាវជ្រាវព័ត៌មានក្នុងផែនទីសិក្សាអំពីស្ថិតិប្រជាជន មុខរបរ ស្ថិតិ ជនពិការជាដើម
- ផ្សារភ្ជាប់សកម្មភាពបង្រៀន និងរៀន ទៅនឹងបណ្ណាល័យ
- ចងក្រងឯកសារស្នាដៃសិស្ស

▪ **ធនធាន**

- ចងក្រងបទពិសោធបំណិនជីវិតផ្សេងៗ
- ប្រជុំបច្ចេកទេស(ថ្ងៃព្រហស្បតិ៍)
- ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធ
- ជម្រុញការធ្វើលំហាត់នៅផ្ទះ
- ផ្សព្វផ្សាយការផលិត និងប្រើប្រាស់សម្ភារឧបទេស ល្បែងសិក្សា
- យកចិត្តទុកដាក់វាយតម្លៃការសិក្សារបស់សិស្ស
- ជម្រុញការសិក្សាផ្នែកបច្ចេកវិទ្យាព័ត៌មាន និងភាសាបរទេស
- ផ្សារភ្ជាប់ខ្លឹមសារមេរៀនពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយ ។

▪ **ការគាំទ្រ**

- ពង្រឹង និងបង្កើតកម្មវិធីបំណិនជីវិតនៅតាមមូលដ្ឋាន( ចិញ្ចឹមសត្វ ដាំដំណាំ គេហវិជ្ជា ...)
- បង្កើតក្លឹបសិក្សា
- រៀបចំទស្សនកិច្ចសិក្សា
- បង្កើតកម្មវិធីសង្គ្រោះបន្ទាន់(មួយឆ្នាំរៀនពីកម្រិត)
- បង្កើតកម្មវិធីឥណទាន
- អនុវត្តកម្មវិធីថ្នាក់គួប
- រៀបចំទិវារំលឹកគុណគ្រូ និងឪពុក ម្តាយ ។

▪ **ការវាយតម្លៃ**

- រៀបចំតេស្តវាយតម្លៃ ផ្អែកលើស្តង់ដាកម្មវិធី
- តាមដានជាប្រចាំលើកម្មវិធីដែលបានអនុវត្ត
- ប្រមូលលទ្ធផលរួចវិភាគរកចំណុចខ្លាំង
  និងចំណុចខ្សោយដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការបន្ត
- ផ្សព្វផ្សាយលទ្ធផលសិក្សារបស់សិស្សរាល់ដំណាច់ឆ្នាំ ។

### គ)សមាសភាគទី៣ ៖ សុខភាព សុវត្ថិភាព និងការការពារកុមារ

▪ **សុខភាព**

- អនុវត្តកម្មវិធីអប់រំកាយកីឡា
- ណែនាំពីវិធី ( ហូបស្អាត រស់នៅស្អាតជាប្រចាំ )
- បង្កើតកម្មវិធីកម្សាន្តផ្សេងៗ
- រៀបចំបរិស្ថានស្អាត ( ទីធ្លា បន្ទប់រៀន... )
- រៀបចំថ្នាក់រៀនមានពន្លឺ និងខ្យល់អាកាសគ្រប់គ្រាន់
- បង្កើតកម្មវិធីប្រឹក្សា ( ជួយកុមារមានបញ្ហា )
- បង្កើតសង្គ្រោះបឋម
- សហការជាមួយមណ្ឌលសុខភាព
- រៀបចំសួនសម្រាប់កុមារពិការ
- ទំនាក់ទំនងជាមួយអង្គការនានាដើម្បីរៀបចំអាហារពេលព្រឹក
- សាង់សងបង្គន់អនាម័យ
- ផ្សព្វផ្សាយអំពីការប្រើប្រាស់គ្រឿងញៀន និងការឆ្លងជម្ងឺផ្សេងៗ
- ផ្សព្វផ្សាយអំពីអាហារូបត្ថម្ភ
- ផ្សព្វផ្សាយការបង្កើតសួនបន្លែតាមគ្រួសារ
- ជម្រុញមាតា បិតាសិស្សឱ្យយកចិត្តទុកដាក់ក្នុងការផ្តល់អាហារពេលព្រឹកដល់កូន ។

▪ **សុវត្ថិភាព និងការការពារ**

អប់រំជាប្រចាំការយល់ដឹងអំពី៖

- សុវត្ថិភាពចំណីអាហារ ភេសជ្ជៈ
- សុវត្ថិភាព សម្ភាររូបវន្ត
- ច្បាប់ចរាចរ
- អំពើ និងល្បែងដែលបណ្តាលឱ្យមានគ្រោះថ្នាក់
- ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការជួញដូរផ្លូវភេទ ជួញដូរកុមារ
- រូបភាពរើសអើង

អប់រំជាប្រចាំការយល់ដឹងអំពី៖

- សុវត្ថិភាពក្នុងការធ្វើពលកម្ម អនាម័យ កីឡាការសម្អាតផ្សេងៗ
- ទារុណកម្ម ទណ្ឌកម្ម ផ្លូវកាយ ផ្លូវចិត្ត អំពើហិង្សា
- គ្រោះថ្នាក់បណ្តាលមកពីគ្រឿងញៀន គ្រឿងផ្ទុះ
- ទំនាក់ទំនងជាមួយអាជ្ញាធរដែនដីដើម្បីទប់ស្កាត់បាតុភាពមិនប្រក្រតី
- បិទពាក្យស្លោក រូបភាពបម្រើឱ្យសុវត្ថិភាព ។

### ឃ) សមាសភាគទី៤ ៖ ការឆ្លើយតបទៅនឹងយេនឌ័រ

▪ **ការបញ្ជ្រាបខ្លឹមសារយេនឌ័រ**

- ផ្សព្វផ្សាយបញ្ញត្តិយេនឌ័រដល់សហគមន៍តាមរយៈការប្រជុំផ្សេងៗ
- បញ្ជ្រាបខ្លឹមសារយេនឌ័រក្នុងគ្រប់សកម្មភាពអប់រំនៅសាលារៀន ។

▪ **ការឧបត្ថម្ភគាំទ្រ និងចូលរួមពីមជ្ឈដ្ឋានពាក់ព័ន្ធ**

- រៀបចំកម្មវិធីគេហកិច្ចដល់កុមារ
- រៀបចំកម្មវិធីឧបត្ថម្ភកុមារក្រីក្រ
- សាងសងបង្គន់អនាម័យដាច់ដោយឡែកសម្រាប់សិស្សស្រី
- រៀបចំកម្មវិធីចុះស្រាវជ្រាវ និងផ្សព្វផ្សាយតួនាទីយេនឌ័រក្នុងជួរសហគមន៍
- រៀបចំកម្មវិធីអប់រំកុមារតូចនៅតាមផ្ទះ ... ។

### ង) សមាសភាគទី៥ ៖ ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍

**ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍**សាលារៀននីមួយៗរៀបចំ និងសម្របសម្រួលឱ្យសិស្សចូលរួម ៖

- រៀបចំក្រុមប្រឹក្សាកុមារដើម្បីជួយគ្រប់គ្រងសាលារៀន
  - បង្កើតក្លឹបសិក្សា
  - រៀបចំពិព័ណ៌ស្នាដៃសិស្ស
  - សកម្មភាពសិល្បៈ កីឡា
- រៀបចំកម្មវិធីលើកស្ទួយការយល់ដឹងអំពីវប្បធម៌ ប្រពៃណីតាមតំបន់ ។

❖ **ការចូលរួមពីគ្រួសារសិស្ស**

- ទស្សនកិច្ចសាលារៀនដើម្បីស្វែងយល់អំពីតម្រូវការសាលារៀន និងការសិក្សារបស់កូន
- ទិវាដឹងគុណឪពុក ម្ដាយ និងគ្រូនៅតាមសាលារៀន
- ជម្រុញការចូលរៀនរបស់កូន និងជួយបង្រៀននៅតាមផ្ទះ
- កម្មវិធីជួយគ្រួសារសិស្សជួបការលំបាក

❖ **ការចូលរួមពីសហគមន៍**

➢ សាលារៀនរៀបចំ និងសម្របសម្រួលឱ្យសហគមន៍ចូលរួម ៖

- បង្កើតក្រុមការងារតាមភូមិដើម្បីអភិវឌ្ឍសាលារៀន
- ប្រមូលកុមារឱ្យចូលរៀន
- សាងសង់ ជួសជុលថែរក្សាសាលារៀន
- ទប់ស្កាត់ការជួញដូរផ្លូវភេទ
- ធ្វើទំនាក់ទំនងជាមួយអង្គការ សប្បុរសជននានាក្នុង និងក្រៅប្រទេសដើម្បីជួយអភិវឌ្ឍសាលារៀន

- ផ្តល់ទីកន្លែង និងជួយរៀបចំសម្របសម្រួលការងារ ទស្សនកិច្ច

➢ ផ្តួចផ្តើមគំនិតធ្វើបុណ្យផ្សេងៗដើម្បីអភិវឌ្ឍសាលារៀន
- បង្កើតហិបឥនិទាន ដើម្បីអភិវឌ្ឍ
- ដោះស្រាយសម្ភារៈសម្រាប់សកម្មភាពបង្រៀន និងរៀន
- រកដំណោះស្រាយ ដើម្បីទប់ស្កាត់អត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សា
- វាយតម្លៃពីការរីកចម្រើនរបស់សាលារៀន ។

## ច) សមាសភាគទី៦ ៖ ការគាំទ្រកម្មវិធីពីប្រព័ន្ធអប់រំ

ការគាំទ្រកម្មវិធីពីប្រព័ន្ធអប់រំ ជាយន្តការការងាររបស់ប្រព័ន្ធគ្រប់គ្រងអប់រំ ដែលធ្វើឱ្យកម្មវិធីសាលាកុមារមេត្រីមានដំណើរការប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ។

❖ ការរៀបចំ និងពង្រឹងរចនាសម្ព័ន្ធ
- រៀបចំគោលនយោបាយស្តីពីកម្មវិធីសាលាកុមារមេត្រី
- រៀបចំគោលការណ៍ណែនាំសម្រាប់អនុវត្ត
- រៀបចំការងារការទទួលខុសត្រូវគ្រប់លំដាប់ថ្នាក់
- ពង្រឹងគណៈកម្មការដែលមានស្រាប់
- រៀបចំឯកសារណែនាំ និងឧបករណ៍ផ្សេងៗសម្រាប់អនុវត្តការងារ
- រៀបចំសាលារៀនដៃគូ កម្រងដៃគូ ស្រុកដៃគូ ខេត្តដៃគូ ។

ការគាំទ្រកម្មវិធីពីប្រព័ន្ធអប់រំ ជាយន្តការការងាររបស់ប្រព័ន្ធគ្រប់គ្រងអប់រំ ដែលធ្វើឱ្យកម្មវិធីសាលាកុមារមេត្រីមានដំណើរការប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ។

❖ **កសាងសមត្ថភាពគ្រប់លំដាប់ថ្នាក់**
- កសាងផែនការ
- បំប៉នកម្មវិធីសាលាកុមារមេត្រី
- ប្រជុំផ្សព្វផ្សាយកម្មវិធីសាលាកុមារមេត្រីគ្រប់អ្នកពាក់ព័ន្ធ
- បំប៉នបច្ចេកទេស តាមដាន វាយតម្លៃការអនុវត្តកម្មវិធីសាលាកុមារមេត្រី
- ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធ ។

ការគាំទ្រកម្មវិធីពីប្រព័ន្ធអប់រំ ជាយន្តការការងាររបស់ប្រព័ន្ធគ្រប់គ្រងអប់រំ ដែលធ្វើឱ្យកម្មវិធីសាលាកុមារមេត្រីមានដំណើរការប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ។

❖ **ការផ្គត់ផ្គង់ថវិកា និងធនធាន**
- លើកទឹកចិត្តតាមគ្រប់រូបភាពចំពោះអង្គភាពណាដែលអនុវត្តការងារល្អប្រសើរ
- ផ្គត់ផ្គង់ថវិកា និងសម្ភារៈ ដើម្បីអភិវឌ្ឍសាលារៀន
- ស្វែងរកមូលនិធិពីប្រភពផ្សេងៗដើម្បីអភិវឌ្ឍសាលារៀន
- គាំទ្រ និងដោះស្រាយតាមគោលការណ៍រាល់សំណូមពររបស់មូលដ្ឋាន ។

ការគាំទ្រកម្មវិធីពីប្រព័ន្ធអប់រំ ដោយន្តការការងាររបស់ប្រព័ន្ធគ្រប់គ្រងអប់រំ ដែលធ្វើឱ្យកម្មវិធីសាលាកុមារមេត្រីមានដំណើរការប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ។

- **ការងារតាមដានវាយតម្លៃ ( ស្វ័យវាយតម្លៃ / វាយតម្លៃពីក្រៅ )**

- បង្កើតឧបករណ៍វាយតម្លៃសម្រាប់វាស់លទ្ធផលការអនុវត្តកម្មវិធីសាលាកុមារមេត្រី
- រៀបចំបណ្តាញអធិការកិច្ចតាំងពីថ្នាក់ក្រសួងដល់មូលដ្ឋានឱ្យបានទៀងទាត់ និងទាន់ពេលវេលា
- បូកសរុបលទ្ធផលការងារ ( ផលប៉ះពាល់ និងរីកចម្រើន ) នៃការអនុវត្តកម្មវិធី ។

## ១០.៤ សន្និដ្ឋាន

ឯកសារកម្មវិធីសាលាកុមារមេត្រី ជាឯកសារដ៏មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍវិស័យអប់រំក្នុងកម្រិតអប់រំមូលដ្ឋានដែលជាការឆ្លើយតបទៅនឹងការអនុវត្តនូវសិទ្ធិរបស់កុមារ និងការលើកកម្ពស់គុណភាពអប់រំនៅកម្ពុជាឲ្យកាន់តែប្រសើរឡើងស្របតាមនិន្នាការនៃការអភិវឌ្ឍការអប់រំសកលលោក។

# សំណួរ

1. តើអ្វីជាសាលាកុមារមេត្រី ?
2. តើកម្មវិធីសាលាកុមារមេត្រីមានគោលបំណងដូចម្តេច ?
3. តើខ្លឹមសារសំខាន់ៗនៃកម្មវិធីសាលាកុមារមេត្រីមានអ្វីខ្លះ ?
4. តើយើងអាចធ្វើឱ្យសាលាយើងក្លាយជាសាលាកុមារមេត្រីបានដោយរបៀបណា ?

# មេរៀនទី១១
# គ្រូបង្រៀនកម្មវិធីសាលាកុមារមេត្រី និងការអភិវឌ្ឍ
# ល្បែងកម្សាន្តក្នុងការសិក្សា

## ១១.១.វត្ថុបំណង

បន្ទាប់ពីសិក្សាមេរៀននេះចប់គរុសិស្សិតនឹង៖

- ពិពណ៌នាអំពីគុណភាពនៃគ្រូបង្រៀនក្នុងសាលាកុមារមេត្រី
- កំណត់ពីវិធីសាស្រ្តផ្សេងៗក្នុងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន
- ពន្យល់ពីតារាងប្រៀបធៀបក្នុងសាលាកុមារមេត្រី
- ជ្រើសរើសពីប្រភេទការកំសាន្តក្នុងការសិក្សាផ្សេងៗដែលជួយសម្រេចគោលបំណងមេរៀន និងធ្វើឱ្យទទួលបានទាំងការកំសាន្ត និងអត្ថប្រយោជន៍
- និងប្រតិបត្តិតាមលក្ខណៈសម្បត្តិរបស់គ្រូសាលា កុមារ មេត្រី ។

## ១១.២ សេចក្តីផ្តើម

យោងតាមកំណើនអត្រាចូលរៀនខ្ពស់ក្រសួងអប់រំ យុវជន និងកីឡាបានខិតខំរកគន្លឹះជាច្រើនទៀត ដើម្បីបង្កើនប្រសិទ្ធភាពបង្រៀន និងរៀនពិសេសបង្កើនអត្រាឡើងថ្នាក់ កាត់បន្ថយអត្រាបោះបង់ការសិក្សា ក្នុងនោះមានកម្មវិធីបំប៉នសិស្សរៀនយឺតស្របពេលតាមរយៈការបង្រៀនបន្ថែមថ្ងៃព្រហស្បតិ៍ ប៉ុន្តែវិធានការទាំងនេះមិនគ្រប់គ្រាន់សម្រាប់ការដោះស្រាយបញ្ហាឡើយ។ ហេតុនេះដើម្បីឲ្យស្របតាមនិន្នាការអប់រំពិភពលោកបច្ចុប្បន្នដែលបានបាញ់ឆ្ពោះទៅលើ ការអនុវត្តសិទ្ធិកុមារជាមូលដ្ឋាន និងពេញលេញដែលធានាដល់ការចូលរៀនរបស់កុមារគ្រប់ប្រភេទប្រកបដោយសមធម៌ និងគ្មានការរើសអើងក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់បង្កើតកម្មវិធីសាលាកុមារមេត្រីនេះឡើង ។

## ១១.៣ ខ្លឹមសារ

### ១១.៣.១ គុណវុឌ្ឍិរបស់គ្រូបង្រៀនសាលាកុមារមេត្រី

❖ **គ្រូបង្រៀនសាលាកុមារមេត្រីត្រូវមានគុណសម្បត្តិដូចខាងក្រោម៖**

- ជាអ្នកមានឥទ្ធិពលក្នុងការអប់រំសិស្សទាំងក្នុងថ្នាក់ និងក្រៅថ្នាក់ ដែលធ្វើគំរូ ដល់មហាជន។
- ត្រូវតែបង្កលក្ខណៈឱ្យកុមារនៅក្នុងថ្នាក់ស្តាប់ និងគោរពតម្លៃនៃបទពិសោធ ទស្សនៈ របស់គ្នាទៅវិញទៅមកគ្មានការរើសអើង និងគ្មានអំពើហឹង្សា។
- ត្រូវតែស្គាល់កុមារគ្រប់រូបនៅក្នុងថ្នាក់រៀនដូចជា៖
    - ស្គាល់ឈ្មោះ
    - ស្គាល់ស្ថានភាពគ្រួសារ
    - ចំណុចខ្លាំង ចំណុចខ្សោយ

- ការចូលចិត្ត ការមិនចូលចិត្ត
- ស្តាប់មតិយោបល់ល្អៗរបស់សិស្ស ។

❖ **ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនជាផ្នែកមួយនៃកម្មវិធីសាលាកុមារមេត្រី**

- ក្រសួងអ.យ.ក បានរៀបចំបំប៉នថ្នាក់ជាតិដល់បុគ្គលិកសិក្សាទាំងអស់អំពីកម្មវិធីសាលាកុមារមេត្រីទោះជាកម្មវិធីនេះមានឬគ្មានលទ្ធផលល្អ អាស្រ័យទៅលើអ្វីដែលគ្រូអនុវត្ត ។
- កសាងឯកសារនៃការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព។
- ឯកសារការអភិវឌ្ឍវិជ្ជាជីវៈ ដែលផ្តល់នូវព័ត៌មានអំពីគំនិតថ្មីៗ នៅក្នុងការបង្រៀន និងរៀន និងឧបករណ៍សម្រាប់អនុវត្តជាក់ស្តែងអំពីរបៀបដែលគ្រូអាចប្រើគំនិតថ្មីៗនៅក្នុងថ្នាក់រៀន។

❖ **សកម្មភាពឆ្លើយតប និងមិនឆ្លើយតបរបស់គ្រូបង្រៀនសាលាកុមារមេត្រី**

| សកម្មភាពមិនឆ្លើយតប | សកម្មភាពឆ្លើយតប |
|---|---|
| ១- មានផែនការបង្រៀនមិនច្បាស់លាស់ | ១- មានផែនការបង្រៀនច្បាស់លាស់<br>+ មានការឆ្លុះបញ្ចាំងរាល់ការបង្រៀន<br>+ មានការស្វ័យវាយតម្លៃ លើលទ្ធផល<br>+ អនុវត្តកម្មវិធីសាលាកុមារមេត្រី ។ |
| ២-មានកិច្ចតែងការបង្រៀនមិនគ្រប់គ្រាន់ | ២-មានកិច្ចតែងការបង្រៀនគ្រប់គ្រាន់គ្រប់មេរៀន។ |
| ៣-មានការរៀបចំបន្ទប់រៀនតែពុំយកចិត្ត ទុកដាក់ឱ្យឆ្លើយតបទៅនឹងមេរៀនតាម ត្រីមាស | ៣- មានការរៀបចំបន្ទប់រៀនប្រកបដោយខ្លឹមសារ សម្បូរបែប និងការផ្លាស់ប្តូរខ្លឹមសាររបស់ខ្លួន១ឆ្នាំ៣ដង |
| ៤-មានការប្រើសំណួរតែភាគច្រើនក្នុង កម្រិតសំណួរចងចាំ និងយល់ដឹង | ៤-មានបំណិនការប្រើសំណួរជំរុញឱ្យសិស្ស ពិចារណាម៉ត់ចត់ថែមលើការយល់ដឹង និងចងចាំ |
| ៥-ផ្តល់ឱកាសមិនគ្រប់គ្រាន់ឱ្យសិស្សចូល រួមសកម្មភាពពិភាក្សាផ្តល់មតិយោបល់ជួយ គ្នាទៅវិញទៅមក។ | ៥-ផ្តល់ឱកាសគ្រប់គ្រាន់ឱ្យសិស្សចូលរួមពិភាក្សាផ្តល់មតិយោបល់សហការគ្នាក្នុងការងារក្រុម និងដៃគូ។ |

| | |
|---|---|
| ៦-បានដាក់លំហាត់ឱ្យសិស្សធ្វើកិច្ចការផ្ទះតាមតែក្នុងសៀវភៅសិសក្សាគោល។ | ៦-ដាក់កិច្ចការផ្ទះឱ្យសសិស្សធ្វើការសិក្សាស្រាវជ្រាវបន្ថែមនៅផ្ទះ។ |
| ៧-ផ្តល់ឱកាសឱ្យសិស្សលេងល្បែងសិក្សា តិចតួចដោយយល់ថាពុំចាំបាច់ខាតពេលវេលាមិនចប់កម្មវិធី។ | ៧-ផ្តល់ឱកាសឱ្យសិស្សចូលរួមសកម្មភាពរៀនសូត្រក្នុងថ្នាក់ និងក្រៅថ្នាក់ឱ្យបានគ្រប់គ្រាន់តាមរយៈការពិភាក្សា និងលេងល្បែងសិក្សា។ |
| ៨- គំនិតច្នៃប្រឌិតពុំទាន់អស់លទ្ធភាពក្នុងការប្រើប្រាស់ធនធាដែលមានស្រាប់ធ្វើជាសម្ភារៈឧបទេសដោយពឹងផ្អែកទៅលើសម្ភារៈទិញនៅផ្សារ។ | ៨- មានបំណិនក្នុងការប្រើប្រាស់ធនជានក្នុងថ្នាក់រៀន និងបរិស្ថានជុំវិញបន្ទប់រៀនឱ្យទៅជាសម្ភារៈឧបទេសសម្បូរបែប។ |
| ៩-យកចិត្តទុកដាក់ជំរុញជួយការសិក្សាសិស្សរៀនយឺតាមរយៈការបង្រៀន ថ្ងៃព្រហស្បតិ៍។ | ៩-ប្រើប្រាស់មធ្យោបាយក្នុងការជួយសិស្សរៀនយឺតតាមរយៈការបង្រៀនបំប៉នថ្ងៃព្រហស្បតិ៍ ។ |
| ១០-មានការរៀបចំប្រធានថ្នាក់ក្រុមវេនសម្អាតប្រចាំថ្ងៃ។ | ១០- មានការរៀបចមរចនាសម្ព័ន្ធក្រុមប្រឹក្សាកុមារតាមរយៈថ្នាក់រៀន និងជំរុញឱ្យមានដំណើរការជាប្រចាំ។ |

### ១១.៣.២ ប្រភេទនៃល្បែងសិក្សា

ល្បែងសិក្សា គឺជាសកម្មភាព ឬជាមធ្យោបាយជួយក្នុងការបង្រៀន និងរៀនយ៉ាងមានប្រសិទ្ធភាពដើម្បីឱ្យគ្រូអនុវត្តសម្រាប់សិស្សនៅគ្រប់កម្រិតថ្នាក់ នៃសាលាបឋមសិក្សា ។

គ្រូអាចផលិតល្បែងសិក្សា ដោយប្រើប្រាស់ធនធានងាយៗមានស្រាប់ តម្លៃថោកដែលមាននៅក្នុងសាលារៀន និងក្នុងសហគមន៍។ វាមានលក្ខណៈបត់បែន តាមតម្រូវការ និងប្រើប្រាស់បានច្រើនដងដោយគ្រូ និងសិស្សគ្រាន់តែយកទៅបង្កើតជារបៀបថ្មីលើសម្ភារៈ នោះតែប៉ុណ្ណោះ ។




## ក) ល្បែងសិក្សាគំរូ

ល្បែងសិក្សាមានច្រើនប្រភេទដែលកុមារចូលចិត្តលេងដើម្បីអនុវត្តលើអ្វីដែលបានរៀនរួចហើយ (ការពង្រឹងបន្ថែម )នូវការអភិវឌ្ឍបំណិននិងការយល់ដឹងផងដែរ (ការពង្រីកបន្ថែមធ្វើឱ្យសម្បូរបែប)។ ល្បែងសិក្សាអាចជំរុញកុមារបន្ថែមទៀតពីលើអ្វីដែលពួកគេបានដឹងរួចមកហើយ ដើម្បីដោះស្រាយបញ្ហាដោយធ្វើការសម្រេចចិត្ត ឬបង្កើតយោបល់ ។ល្បែងទាំងនេះធ្វើឱ្យកុមារមានការពិចារណាហ្មត់ចត់ ។ ភាគច្រើននៃល្បែងទាំងនេះអាចប្រើសម្ភារៈងាយៗដូចជាក្តារឆ្នូតតូច ប័ណ្ណ សន្លឹកក្រដាស ឬវត្ថុផ្សេងៗ...។

- ❖ **ល្បែងសិក្សាទាំងបីប្រភេទមាន៖**

| ប្រភេទល្បែង | បរិយាយ |
| --- | --- |
| ផ្គូផ្គង | - រកគូនៃវត្ថុដូចគ្នា ( រូបភាព ប័ណ្ណពាក្យ កន្សោមពាក្យ...) រកវត្ថុដែលខុសប្លែកពីគេ |
| រៀបតាមលំដាប់ | - រៀបឬដាក់វត្ថុ( រូបភាព ប័ណ្ណពាក្យ កន្សោមពាក្យ...) តាមលំដាប់លំដោយអនុវត្តតាមច្បាប់គោលការណ៍ ឬវិធីធ្លាប់អនុវត្តលេង |
| ធ្វើចំណែកថ្នាក់ | - ផ្គុំវត្ថុ( រូបភាព ប័ណ្ណពាក្យ កន្សោមពាក្យ...) ដោយអនុវត្តតាមលក្ខណៈ ឬនិយមន័យ |

**បញ្ជាក់:** ក្រៅពីល្បែងសិក្សាទាំងបីប្រភេទខាងលើ គ្រូអាចបង្កើតប្រភេទល្បែងសិក្សាផ្សេងៗទៀតតាមការច្នៃប្រឌិតនិងលទ្ធភាពរបស់ខ្លួនដូចជា ល្បែងប្រដេញពាក្យ ល្បែងពាក្យប្រដៅ...។

## ខ) របៀបលេងល្បែង

- ប្រាប់ចំណងជើងល្បែង

- ឱ្យសិស្សលេងជាក្រុម ឬដៃគូ (រយៈពេល១០នាទី )
- គ្រូណែនាំពីរបៀបលេង
- សិស្សអនុវត្តលេង (គ្រូដើរត្រួតពិនិត្យ )
- របាយការណ៍ជាបុគ្គល ឬក្រុមក្រោយពេលលេង
- ផ្សារភ្ជាប់លទ្ធផលក្រោយពេលលេងទៅជាមួយខ្លឹមសារមេរៀន ។

## ១១.៤ សន្និដ្ឋាន

ល្បែងសិក្សាមានសារៈសំខាន់ណាស់ ចំពោះគ្រូ និងសិស្សក្នុងការបង្រៀន និងរៀន ព្រោះការលេងល្បែងសិក្សាធ្វើឱ្យសិស្សសប្បាយរីករាយ ចេះធ្វើការជាមួយគ្នា ចេះជួយគ្នា ចេះសហការគ្នា ចេះផ្លាស់ប្តូរបទពិសោធទៅវិញទៅមក និងពង្រឹងចំណេះដឹងបន្ថែមដល់ការរៀនសូត្រ ។

# សំណួរ

1. តើគុណភាពនៃគ្រូបង្រៀនក្នុងសាលាកុមារមេត្រីមានអ្វីខ្លះ ?
2. តើមានរបៀបអភិវឌ្ឍន៍វិជ្ជាជីវៈអ្វីខ្លះដែលគ្រូបង្រៀននៃសាលាកុមារមេត្រីត្រូវមាន ?
3. តើការកំសាន្តក្នុងការសិក្សាមានអត្ថប្រយោជន៍បែបណាខ្លះដល់ការបង្រៀន និងការសិក្សា ?

# មេរៀនទី១២
# ការអប់រំភាពជាពលរដ្ឋសកល
# (រួមបញ្ចូលប្រភេទទាំង៣ BLUE នៅក្នុងខ្លឹមសារមេរៀន ១ ម៉ោង)

## ១២.១ វត្ថុបំណង

បន្ទាប់ពីការសិក្សា គរុនិស្សិតនឹង៖

- ពិពណ៌នាអំពីបរិស្ថាននៃទីតាំងដែលត្រូវបានរៀបចំ និងរបៀបដែលវាទាក់ទងទៅនឹងសកលលោក និងការណែនាំអំពីគំនិតនៃសញ្ញាតិសកល
- ការអង្កេតលើមូលហេតុនៃការព្រួយបារម្ភជាសកលទូទៅ និងផលប៉ះពាល់លើជាតិសាសន៍ និងទីតាំង
- ពិភាក្សាអំពីទំនាក់ទំនងនៃរចនាសម្ព័ន្ធអភិបាលកិច្ចពិភពលោក ជាមួយនឹងរចនាសម្ព័ន្ធជាតិមូលដ្ឋាន និងការស្វែងរកភាពជាពលរដ្ឋសកល ។

## ១២.២ សេចក្តីផ្តើម

## ១២.៣ ខ្លឹមសារ

### ១២.៣.១ ប្រព័ន្ធ និងរចនាសម្ព័ន្ធក្នុងស្រុក ជាតិ និងសកល

- **ថ្នាក់មុនបឋមសិក្សា និងបឋមសិក្សាកម្រិតទាប**
    - វត្ថុបំណងនៃការសិក្សា៖ រៀបរាប់ពីរបៀបដែលបរិស្ថានមូលដ្ឋានត្រូវបានរៀបចំ និងរបៀបផ្សារភ្ជាប់ទៅពិភពលោកធំធេងជាមួយនឹងការណែនាំអំពីទស្សនៈនៃភាពជាពលរដ្ឋ។
    - ខ្លឹមសារ ៖
        - ខ្លួនឯង គ្រួសារ សាលា ភូមិស្ថាន សហគមន៍ ប្រទេស ពិភពលោក
        - របៀបដែលពិភពលោកត្រូវបានរៀបចំ (ក្រុម សហគមន៍ ភូមិ ក្រុង ប្រទេស តំបន់)
        - ទំនាក់ទំនង សមាជិកភាព ការធ្វើច្បាប់ និងការចូលរួម (គ្រួសារ មិត្តភក្តិ សាលា សហគមន៍ ប្រទេស ពិភពលោក
